# មជ្ឈមណ្ឌលឯកសារកម្ពុជា

## *សែម ហឿន ហៅ គីម* **I 00569**

## *មុខងារ ៈ លេខាអនុសេនាធំ*

## *ជួបសម្ភាសជាមួយលោកតា សែម ហឿន អាយុ៥២ឆ្នាំ ជាម្ចាស់ប្រវត្តិរូប*

## *រស់នៅក្នុងភូមិអណ្តូងត ឃុំបាក់ស្នា ស្រុកបារាយណ៍ ខេត្តកំពង់ធំ*

## *ធ្វើនៅថ្ងៃទី ២៨ កុម្ភៈ ២០០៥*

## *សម្ភាសដោយៈ ដាន់ សុជា*

*សុជាៈ* ខ្ញុំគឺជាបុគ្គលិកមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាណាពូ ខាងស្រាវជ្រាវប្រវត្តិសាស្ត្រយើងជំនាន់ខ្មែរក្រហម ហើយខ្ញុំមកសួរពូនេះគឺចង់ដឹងពីប្រវត្តិរបស់ពូដែលរស់នៅក្នុងជំនាន់ហ្នឹង ដើម្បីយកទៅសរសេរជាឯកសារទុកទៅថ្ងៃក្រោយអោយក្មេងៗ បានដឹងថាអ្នកដែលទៅធ្វើការនៅជំនាន់ហ្នឹងអីយ៉ាងម៉េចៗណាពូ?

*ហឿនៈ* សម័យប៉ុលពតដែលខ្ញុំបានចូលទៅគឺខ្ញុំនៅអាយុ១៩ ខ្ញុំចូលទៅគឺនៅក្នុងថ្ងៃ៤ខែ៤ឆ្នាំ៧០ ។

*សុជាៈ* អញ្ចឹងខ្ញុំសួរពូ តើពូមានឈ្មោះអីដែរពល់ថ្ងៃនេះ?

*ហឿនៈ* ឈ្មោះហឿន ។

*សុជាៈ* ឈ្មោះអីហឿន?

*ហឿនៈ* សែម ហឿន ។

*សុជាៈ* ពូកើតនៅឆ្នាំណាដែរ?

*ហឿនៈ* កើតនៅឆ្នាំប៉ុន្មានទេប្អូនឯងដកមើលៗ ។

*សុជាៈ* ឆ្នាំខ្មែរឆ្នាំអីដែរ?

*ហឿនៈ* ឆ្នាំខ្មែរខ្ញុំកើតនៅឆ្នាំមមី ។

*សុជាៈ* មកដល់តើអាយុប៉ុន្មានហើយ?

*ហឿនៈ* ខ្ញុំអាយុ៥២ ។

*សុជាៈ* ពូកើតជានៅភូមិណាដែរ?

ហឿនៈ កំណើតកើតជានៅភូមិបាក់ស្នាក្រោម ។

សុជាៈ ឃុំ?

ហឿនៈ ឃុំបាក់ស្នា ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

សុជាៈ ចុះរាល់ថ្ងៃលោកពូរស់នៅក្នុងភូមិអីដែរ?

ហឿនៈ រាល់ថ្ងៃខ្ញុំរស់នៅក្នុងភូមិអណ្តែត ។

សុជាៈ ឃុំ?

ហឿនៈ ឃុំបាក់ស្នា ។

សុជាៈ ស្រុក?

ហឿនៈ ស្រុកបារាយណ៍ ។

សុជាៈ ស្រុកបារាយណ៍ខេត្តកំពង់ធំដដែល?

ហឿនៈ បាទ ។

សុជាៈ ឪពុកពូឈ្មោះអីដែរ?

ហឿនៈ ឪពុកខ្ញុំឈ្មោះសែម ។

សុជាៈ ចុះម្តាយ?

ហឿនៈ ម្តាយឈ្មោះឃុត ។

សុជាៈ ពូមានបងប្អូនប៉ុន្មាននាក់?

ហឿនៈ បងប្អូនខ្ញុំ៤នាក់ ។

សុជាៈ ចុះរាល់ថ្ងៃនៅរស់ប៉ុន្មាននាក់?

ហឿនៈ សព្វថ្ងៃនៅសល់តែពីរទេ ។

សុជាៈ មួយនៅរស់និងឈ្មោះអីគេដែរ?

ហឿនៈ ឈ្មោះស្រីសុទ្ធ ។

សុជាៈ ស្រីឬប្រុស?

ហឿនៈ ស្រី ។

សុជាៈ ចុះបាត់ពីរនាក់នោះ?

ហឿនៈ មួយបងទី៣គាត់ស្លាប់ដោយរោគជំងឺរបស់គាត់ ហើយបងទី១ស្លាប់ដោយសារប៉ុលពតសម្លាប់ ។

សុជាៈ ឈ្មោះអីគេដែរ?

ហឿនៈ ឈ្មោះអំ ចេស ។

សុជាៈ ចេសហៅអំហ៊ឹងហ៎?

ហឿនៈ ចា៎ៗ!

សុជាៈ រាល់ថ្ងៃពូមានកូនចៅប៉ុន្មាននាក់?

ហឿនៈ មាន៩នាក់ ។

សុជាៈ ប្រពន្ធឈ្មោះអីដែរ?

ហឿនៈ ប្រពន្ធឈ្មោះ ឡុំ លី ។

សុជាៈ អាយុប៉ុន្មានហើយ?

ហឿនៈ អាយុ៤១ ។

សុជាៈ គាត់នៅនិងផ្ទះនិងដែរ រាល់ថ្ងៃនេះ?

ហឿនៈ គាត់នៅនៃផ្ទះនិងដែរ ។

សុជាៈ ពូប្រកបរបរធ្វើការអីដែរ?

ហឿនៈ ខ្ញុំប្រកបរបរធ្វើស្រែចំការធម្មតាទេបង ។

សុជាៈ ចុះក្រៅពីធ្វើស្រែ?

ហឿនៈ ក្រៅពីធ្វើស្រែទៅធ្វើចំការបន្តិចបន្តួច ។

សុជាៈ មានដីចំការដែរ?

ហឿនៈ ដីចំការគាប់នៅត្រើយម្ខាងណោះ ។

សុជាៈ ជិតស្ទឹង?

ហឿនៈ បាទជិតស្ទឹង ។

សុជាៈ ស្ទឹងអីគេអាននឹង?

ហឿនៈ ស្ទឹងនេះ ស្ទឹងជិនិតយើងនេះ ។

សុជាៈ ហូរពីណាមកដែរ?

ហឿនៈ ហូរពីភ្នំដីពីក្បាលទឹកដី ។

សុជាៈ ចុះពូកាលដែលនៅតូចពូមានបានរៀនអីដែរអត់?

ហឿនៈ កាលនៅពីរតូចពូបានរៀនត្រឹមថ្នាក់ទី១២ពីសង្គមទេ ។

សុជាៈ ហើយពូមានបានបួសទេ?

ហឿនៈ   បួសអត់បានទេ ព្រោះសម័យប៉ុលពតកើតឡើងទៅគេរសាយពីសង្ឃទៅក៏អត់បានបួសទៅ ។

សុជាៈ   អញ្ចឹងអត់បានបួសទេ?

ហឿនៈ   និងហើយ ។

សុជាៈ   កាលរៀនពូរៀននៅឯណាដែរ?

ហឿនៈ   រៀននៅបាក់ស្នា ។

សុជាៈ   រៀនបានតែមួយឆ្នាំទេ?

ហឿនៈ   បាទ! ។

សុជាៈ   ហើយកាលរៀននិងឈប់ដោយសារមូលហេតុអីដែរ?

ហឿនៈ   ឈប់ដោយសារកើតសង្គ្រាម ដល់ពេលដល់ឆ្នាំ១៩៦៨និងស្រុកផ្ទុះសង្គ្រាមកើតខ្មែរក្រហម ចលាចលពេញភូមិពេញស្រុកទៅក៏បែកបាក់ទៅរំសាយដួរទៅ ក៏អត់បានរៀនទៅ ។

សុជាៈ   ចុះឈប់ពីរៀនតើពូធ្វើអីគេ?

ហឿនៈ   ឈប់ពីរៀនខ្ញុំចូលធ្វើទាហានប៉ុលពតតែម្តង ។

សុជាៈ   អត់មានថាដូចនៅធ្វើស្រែទេ?

ហឿនៈ   អត់មានបាននៅធ្វើស្រែចំការអីទេ ។

សុជាៈ   ពូចូលធ្វើទាហាននៅឆាំ៧០ហ្នឹង?

ហឿនៈ   បាទ! នៅឆ្នាំ៧០ ។

សុជាៈ   មុនដំបូងគេអោយធ្វើអីដែរ?

ហឿនៈ   មុនដំបូងបងនៅជាយុទ្ធជនធម្មតាទេ ចូលទៅសមរភូមិនៅកំពង់ថ្មនេះ ។

សុជាៈ   អានិងនៅក្នុងកងអីវអីដែរ?

ហឿនៈ   អានិងអត់ទាន់នៅអីទេ ដូចថានៅកងទ័ពស្រុក ។

សុជាៈ   ពីណាគេជាប្រធានគ្រប់គ្រងទ័ពស្រុកហ្នឹង?

ហឿនៈ   ប្រធានឈ្មោះកួរ ។

សុជាៈ   ចុះពូមានឋានៈជាអីដែរ?

ហឿនៈ   ខ្ញុំនៅជាយុទ្ធជន ។

សុជាៈ   ហើយវៃនៅកំពង់ថ្មនិងយូរទេ?

ហឿនៈ វៃកំពង់ថ្មចេនឡានិងវៃ១ឆ្នាំ វៃ១ឆ្នាំហើយបានបញ្ចប់អាចេនឡានិងទៅបានគេបញ្ជូនខ្ញុំទៅធ្វើទ័ពនៅមជ្ឈិម ។

សុជាៈ ឆ្នាំណាដែលមកវៃនៅកំពង់ថ្មនេះ?

ហឿនៈ មកវៃនៅឆ្នាំ៧១ ។

សុជាៈ អ៊ំពាងពូចូលទៅបានជិត១ឆ្នាំដែរ បានគេអោយចូលទៅសមរភូមិ?

ហឿនៈ បាទ! ។

សុជាៈ ចុះគេមានបង្ហាត់បង្រៀនយុទ្ធសាស្រ្តអីដែរ?

ហឿនៈ គេមុនដំបូងគេបង្ហាត់ក្បាច់យោធានិងយុទ្ធសាស្រ្តហ្នឹង ។

សុជាៈ ហើយពេលដែលពូចូលទៅបក្សបដិវត្តន៍ដំបូងនិង ពូចូលទៅដោយសារមូលហេតុអីដែរ?

ហឿនៈ កាលនិងវាចេះ គេឃោសនាថាកងទ័ពរណៈសិរ្សរំដោះសម្តេចឪយើងនិងណា៎ អ៊ំញ្ចឹងបងក៏មានអាឧត្តមគតិមួយថាចង់រំដោះប្រទេសជាតិក៏ចូលទៅ ។

សុជាៈ កាលនិងតាមរយៈពីណាគេដែរ?

ហឿនៈ ខ្ញុំចូលតាមរយៈណែ៎ ហ៊ីក្មេចឈ្មោះគាត់ទៀត ។

សុជាៈ គាត់មានឋានៈជាអីដែរ?

ហឿនៈ ជាប្រធានយោធាស្រុក អ៊ឺ!គាត់ឈ្មោះទុន ។

សុជាៈ ឈ្មោះទុន!

ហឿនៈ ពេលដែលចូលទៅប៉ុន្មាននាក់ អ្នកដែលនៅក្នុងភូមិដែលចូលទៅជាមួយនិងពូ?

សុជាៈ ចូលទៅមានគ្នា៤នាក់?

ហឿនៈ អាយុប្រហែលជាប៉ុន្មានដែរ ។

សុជាៈ ហើយទៅដំបូងគេមានបង្រៀនពីនយោបាយអីដែរ?

ហឿនៈ ទៅដំបូងគេបំពាក់បំប៉នពីនយោបាយគេតែរឿងប្រយុទ្ធជាមួយខ្មាំងទេ អោយយើងវាវីងស្វារតីកុំអោយខ្លាចខ្មាំងខ្លាចអី គេអត់មានបំពាក់បំប៉ននយោបាយអីផ្សេងៗអត់ទេ អោយយើងពង្រឹងគោលជំហប្រឹងប្រយុទ្ធតស៊ូ ដែលថារំដោះទឹកដីរំដោះប្រទេសជាតិ ។

សុជាៈ ហើយម្តាយឪពុកពូមានអារម្មណ៍យ៉ាងម៉េចដែរពេលដែលពូចេញទៅដំបូង?

ហឿនៈ គឺគាត់បារម្ភណ៍ គាត់ព្រួយត្រង់ថាពូទៅសមរភូមិគាត់ខ្លាចពូមានគ្រោះថ្នាក់ដលពាក់លីជីវិតណា៎ ឬមួយជាពិការ ដូចថាស្លាប់នៅសមរភូមិអីគាត់មានអារម្មណ៍ដែរ ។

សុជាៈ ហើយគ្រួសារពូគឺទៅតែពូម្នាក់ឯងទេ?

ហឿនៈ បាទ! ទៅតែម្នាក់ឯងទេ គឺខ្ញុំហើយនិងបងបង្កើតមួយហ្នឹង ។

សុជាៈ អូ! បងពូឈ្មោះអំហ្នឹង?

ហឿនៈ បាទ! ឈ្មោះអំ ហៅចេស ។

សុជាៈ គាត់ទៅមុនពូ?

ហឿនៈ គាត់ទៅក្រោយខ្ញុំទេ ។

សុជាៈ អញ្ចឹងចូលទៅចូលជាយោធាស្រុក?

ហឿនៈ ចូលទៅយោធាស្រុក ។

សុជាៈ មុនឡើងទៅ គេអោយវៃនិងពូហាត់រៀនយូរដែរបាន៥-៦ខែដែរ?

ហឿនៈ បានរយៈតែ៣ខែ ។

សុជាៈ មុនដំបូងគេអោយឡើងវៃឬក៏មានវែកបាយស្មុកអីដែរ?

ហឿនៈ អត់មានវែកទេ ចូលទៅសមរភូមិបណ្តោយកាន់កាំភ្លើងបណ្តោយ ។

សុជាៈ នៅពេលឆ្នាំណាដែល ចូលសមរភូមិនៅកំពង់ថ្មបានតែមួយដងនិងទេ?

ហឿនៈ បាទ! រហូតចប់សមរភូមិកំពង់ថ្មទៅបានគេបញ្ជូនពូទៅសមរភូមិនៅកំពង់ចាម ។

សុជាៈ នៅឆ្នាំណាដែរ?

ហឿនៈ នៅឆ្នាំ១៩៧១ ។

សុជាៈ អានិងចុងឆ្នាំហើយ?

ហឿនៈ និងហើយ ។

សុជាៈ អានិងជាទ័ពអីវិញ?

ហឿនៈ នៅជាទ័ពមជ្ឈឹម ។

សុជាៈ ពីណាគេជាអ្នកគ្រប់គ្រងទ័ពមជ្ឈឹមហ្នឹង?

ហឿនៈ គ្រប់គ្រងឈ្មោះភឿង ។

សុជាៈ ហឿងឬក៏អឿន!

ហឿនៈ ភឿង ។

សុជាៈ ភឿនវិញ ។

ហឿនៈ បាទ! ប្រធានកងពលឈ្មោះអឿន ប្រធានវរៈសេនាតូចឈ្មោះភឿន ។

សុជាៈ ហើយទៅដល់កំពង់ចាប់ ពូចូលសមរភូមិនៅមួយដុំណា?

ហឿនៈ សមរភូមិនៅកំពង់ចាម ខ្ញុំវៃនៅក្នុងស្រុកភ្នំស្រ៉ ។

សុជាៈ វៃនៅឯណាទៀត?

ហឿនៈ មកវៃនៅបន្ទាយស៊ុប ។

សុជាៈ បន្ទាយស៊ុបនៅនិងខេត្តនិងហ្ន៎?

ហឿនៈ បាទ! រហូតពីនិងមកទៅវៃនៅព្រែកដើមចាន់ ។

សុជាៈ នៅនិងកំពង់ចាមនិងដែរ?

ហឿនៈ បាទ! ។

សុជាៈ នៅស្រុកណាពូស្គាល់ទេ?

ហឿនៈ អត់ស្គាល់ដែរ បងអត់ស្គាល់ដែរមិនដឹងជានៅក្នុងស្រុកណា ។

សុជាៈ អត់ទាន់ឆ្លងទន្លេទេ?

ហឿនៈ អត់ឆ្លងទេនៅត្រើយខាងយើងនិងដែរ ចប់ពីព្រែកដើមចាន់បានបកមកវៃនៅបន់ធាយ ។

សុជាៈ វៃនៅបន់ធាយជិតដល់ភ្នំពេញ?

ហឿនៈ បាទ!បាទ! វៃរយះមួយខែកន្លះបានបងបកទៅវៃនៅព្រែកក្តាម ប្រហែលជាពីរខែបានបញ្ជូនបងទៅវៃនៅកំពង់លួងនៅខត្តុងអស់រយះ៣ខែ ៣ខែបានដកបងទៅសមរភូមិនៅសៀមរាប ។

សុជាៈ ឆ្នាំណាពូមាននៅចាំទេ?

ហឿនៈ នៅឆ្នាំ១៩៧២ ចុងឆ្នាំ៧២ហើយ ។

សុជាៈ អានិងយើងទៅទាំងវរៈទាំងអីហ្នឹង?

ហឿនៈ បាទ! ទៅទាំងវរៈទាំងកងពល ។

សុជាៈ ហើយពូនៅក្នុងកងពិសេសឬក៏?

ហឿនៈ នៅកងកាំភ្លើងធំ អានេះគេដកពីថ្មើរជើងបានបញ្ជូនបងទៅកាន់សៀមរាប បងទៅកាន់កាំភ្លើងធំមួយដង ។

សុជាៈ ពីណាគេប្រធាន?

ហឿនៈ ប្រធានខ្ញុំហ្នឹង ។

សុជាៈ ឈ្មោះភឿននិងហ្ន៎?

ហឿនៈ ប្រធានវរៈសេនាតូចឈ្មោះភឿន ប្រធានកងពលឈ្មោះអឿន ។

សុជា៖ ទៅវៃនៅសៀមរាបបានប៉ុន្មានខែ?

ហឿន៖ ទោរយៈ១ឆ្នាំ ។

សុជា៖ អូ!វៃយូរដែរ?

ហឿន៖ បាទ! វៃយូរ ទោឈដើរនៅសមរភូមិនៅកំពង់ថ្កូវ មកពីកំពង់ថ្កូវមកឈរជើងនៅកោះលូង ។

សុជា៖ មកព័ទ្ធទីរួមខេត្ត?

ហឿន៖ មកព័ទខេត្តរួច បានបង់ឡើងទៅវៃភ្នំប្រុសភ្នំស្រីខាងទន្លេសាប ឆ្លងពីទន្លេសាបមកបានបង់វៃនៅដែលគេហៅថាតំណាក់ស្តេច ។

សុជា៖ អានិងនៅក្នុងអី?

ហឿន៖ នៅក្នុងខេត្តសៀមរាបនិងដែរ វាទល់និងខេត្តបាត់ដំបងមកពីនិងមកបានបង់វៃនៅស៊ីងស្រុក ។

សុជា៖ ស៊ីងស្រុកនិងនៅឯណាដែរ?

ហឿន៖ នៅក្នុងខេត្តសៀមរាបដែរ ។

សុជា៖ ស្រុកអីគេអាហ្នឹង?

ហឿន៖ គេហៅស្រុកពក់

សុជា៖ អានិងវៃប្រឆិតទៅអិញ្ចេះ?

ហឿន៖ បាទ! វៃប្រឆិតទៅប្រនេតព្រះ ចេញពីនិងមកបានបង់វៃឡើងទៅឧត្តមានជ័យវៃប្រច្រាសទៅដើងទៅវិញ ចេញពីនិងមកបានបង់ចេញទៅវៃនៅ គេហៅថាស្វាយរមៀត ។

សុជា៖ ស្វាយរមៀតនិងនៅឯណា?

ហឿន៖ ស្វាយរមៀតនិងនៅតំបន់អង្គរ មកការពារនៅតំបន់អង្គរ ។

សុជា៖ អង្គរវត្តហ្នឹង?

ហឿន៖ បាទ! ។

សុជា៖ ចុះវៃទៅអង្គរវត្តអិញ្ជឹងដូចថាប្រសាទអីនិង បើសិនជាទ័ពលន់ណុលអីនៅនិងប្រសាទនិងតើវៃចូលទេ?

ហឿន៖ វៃចូល វានៅលើភ្នំបាក់ខែង បកពីនិងគេដកបង់មកកងពិសេសវិញ កងពិសេសនិងវៃអត់មានកាំភ្លើងទេ មានតែគ្រាប់បែកទេឡើងវៃលើភ្នំនិងណា វៃភ្នំបាក់ខែងនិងវៃដាច់ភ្នំបាក់ខែងហើយគេដកបង់ម្នាក់មកទៀត គេដកបង់ពីកងពិសេសមកកាន់កាំភ្លើងបាញ់យន្តហោះនៅលើភ្នំបាក់ខែងហ្នឹងអស់រយៈ៣ខែ ។

សុជាៈ ចុះពូថាវៃនៅសៀមរាបបាន១ឆ្នាំនិងវាដល់ឆ្នាំ៧២-៧៣ជិតចល៧៤ហើយ?

ហឿនៈ បា៎! វៃឆ្នាំ៧៣អាមេរិកសុំចចារដកយន្តហោះចេញ បានបងចេញទៅវៃនៅកំពង់ស្ពឺទៅនៅកំពង់ស្ពឺអស់រយៈ៣3ខែ វៃនៅអន្លង់ស្នួលវៃនៅបែកចាន ករក្អមសុទ្ធតែជាខ្មែរក្រហមវាត់ភ្នំពេញទាំងអស់ ដកពីករក្អមមកបានទៅវៃនៅព្រែកក្មៅ វៃនៅនិងចប់មកបានទៅវៃនៅអាសីជ្រោយស្រុកមុខកំពូល ។

សុជាៈ កាលនិងពូនៅក្នុងអង្គភាពពិសេសប្ញក៏?

ហឿនៈ អានិងនៅកាំភ្លើងធំ នៅខាងកាំភ្លើងធំខាងបាញ់អាមេរីន ។

សុជាៈ ហើយពូមានឋានៈជាអីគេ?

ហឿនៈ ខ្ញុំនៅជាប្រធានយោធាកងតូច ។

សុជាៈ ដូចថានៅវៃនៅសៀមរាបអិញ្ចឹង វៃបត់ទៅខាងព្រះនេតព្រះទៅបាត់ដំបងហើយវៃឡើងទៅដល់ឧត្តរមានជ័យអិញ្ចឹង ដូចថាតើមានទ័ពគេវៃពីខាងលើមកវិញដែរអត់ទ័ពខ្មែរក្រហមណា?

ហឿនៈ បងនៅទ័ពខាងមជ្ឈិមនិងគឺសហការណ៍វៃជាមួយទ័បតំបន់ណាដែលគេឈរជើងនៅហ្នឹង ។

សុជាៈ ទ័ពខាងមជ្ឈិមខាងយើងនៅខាងភូមិភាគឧត្តរនេះដីវៃតំបន់ណាខ្លះទៅ?

ហឿនៈ ក្នុងកងទ័ពមជ្ឈិមនិងគឺថាវៃបានគ្រប់ខេត្តទាំងអស់ អោយតែខេត្តណាកងទ័ពខ្សោយគេដកកងទ័ពដែលខ្លាំងនិងទៅជួយវៃ ដូចនៅខាងបូព៌ាអិញ្ចឹងខ្សោយខាងកងទ័ពគេដកពួកបងនិងអោយទៅជួយអិញ្ចឹងតែហ្នង ។

សុជាៈ តែឋិតនៅក្នុងកងពលរបស់អឿននិងដែលទេ?

ហឿនៈ បា៎! នៅនិងកងពល៣១០និងដដែលទេ កាលនិងបងនៅឋិតជាប់និងសម្តេចនាយកហ្នឹង ។

សុជាៈ សម្តេចហ៊ុនសែនហ្នឹង?

ហឿនៈ បា៎! ខ្ញុំឡើងទៅវរៈសេនាតូចគាត់នៅជាប្រធានយោធាកងពល អឿនជាប្រធានសម្តេចគាត់នៅជាអនុកងពល៣១០ហ្នឹង ។

សុជាៈ ហើយអីបានពូដឹងថាគាត់ជាសម្តេចនាយក?

ហឿនៈ ព្រោះស្គាល់គ្នាច្បាស់ ដែលគាត់មានពិការភ្នែកហ្នឹងប្រយុទ្ធនៅជាមួយបងដែលគេហៅថាប្រទាយដាំស្លែង ។

សុជាៈ នៅម្តុំណាដែរ?

ហឿនៈ នៅម្តុំដាំស្លែងនៅខាងត្បូង អ៎!ដើងពេញចាំ ។

សុជាៈ ចុះគាត់ថាគាត់ពិការនៅ?

ហឿនៈ អត់ទេពិការនៅជាមួយខ្ញុំខ្ញុំហ្នឹង ត្រូវអំបែងគ្រាប់សុវាន់ធីណៃប៉ប៊ុនជើងធូក ។

សុជាៈ ចំកន្លែងណា?

ហឿនៈ ចំក្បាលគាត់ ។

សុជាៈ ចំក្បាលម៉េចក៏មកខ្ទះភ្នែក?

ហឿនៈ វាចំសរសៃប្រសាទ ។

សុជាៈ ហើយពូចាំមុខគាត់រហូតមកដល់រាល់ថ្ងៃហ្នឹង?

ហឿនៈ ចាំរាល់ថ្ងៃ ខ្ញុំចាំរាល់ថ្ងៃតើ ។

សុជាៈ ចុះគាត់ចាំពូទេ?

ហឿនៈ ប្រហែលជាភ្លេចហើយ ព្រោះអស់រយៈកាលយូរហើយវាមិនដែលបានទំនាក់ទំនង ម្យ៉ាងដូចថាពូខ្វះអាខាងថវិការដើម្បីទំនាក់ទំនងទៅក៏ដាច់គ្នាទៅ តែចំពោះគាត់និងខ្ញុំច្បាស់ណាស់អត់មានស្រពិចស្រពិលទេ ។

សុជាៈ គាត់ថ្នាក់លើពូ?

ហឿនៈ បាទគាត់ថ្នាកលើខ្ញុំ ។

សុជាៈ ចុះមិនមែនគាត់នៅខាងបូព៌ាទេ?

ហឿនៈ អត់ទេគាត់នៅខាងឧត្តរ ។

សុជាៈ កាលនិងគាត់ឈ្មោះអីគេ?

ហឿនៈ ឈ្មោះសែនដដែលហ្នឹង ប៊ុនគាត់តែអញ្ចឹងតាំងពីដើមមកស្កុមតែចឹងអត់សូវដែលមានសាច់ទេ ។

សុជាៈ ចុះពូពេលដែលពូវៃចូលដល់ភ្នំពេញឆ្នាំ៧៥ តើពូវៃនៅកន្លែងណាអាហ្នឹង?

ហឿនៈ វៃនៅព្រែកភ្នៅ ផ្លូវរទេះភ្លើង ។

សុជាៈ ចុះពេលវៃចូលទៅភ្នំពេញ តើពូវៃចូលទៅតាមច្រកណា?

ហឿនៈ តាមប៉ុស៍រាជ្យ តាមវត្តភ្នំហ្នឹង ។

សុជាៈ កាលនិងពូមានឋានៈជាអីដែរ?

ហឿនៈ ខ្ញុំនៅជាប្រធានយោធាវរៈសេនាតូចហើយ ។

សុជាៈ វរៈសេនាតូចលេខប៉ុន្មានដែលពូ?

ហឿនៈ វរៈសេនាតូចលេខ៣០៧ ។

សុជាៈ នៅកងពល៣១០ហ្នឹង?

ហឿនៈ បាទនៅកងពល៣១០ហ្នឹង ជិតភ្លេចអស់ហើយបងព្រោះវាអស់រយះកាលយូរហើយ ។

សុជាៈ ចុះដល់ពេលចូលទៅដល់ទីក្រុងភ្នំពេញចឹង អ៊ីមានគេប្រាប់ពីលើមកឬក៏ទទួលបញ្ជាមកថាអោយជំលាសប្រជាជនចេញអីមានបានទទួលបញ្ជាអញ្ចឹងទេ?

ហឿនៈ អានិងរឿងផ្នែកទ័ពខាងមជ្ឈឹមអានិងបងអត់ដឹងទេ អារឿងផែនការត្រូវជំលាសប្រជាជនចេញពីទីក្រុងភ្នំពេញចេញមកអានិងគេខាងសន្តិសុខគេខាងស្រុកណា អញ្ចឹងគេចាប់ជំលាសប្រជាជនមកគេមកក្តោបក្តាប់តែទ័ព ចំពោះបងដែលជាអ្នកប្រយុទ្ធនៅសមរភូមិគឺអត់ដឹងទេ គឺការពារតែសមរភូមិមក ។

សុជាៈ ចុះអាពេលដែលយើងចូលទៅភ្នំពេញនិងមិនមានប្រជាជនចេញមក?

ហឿនៈ ប្រជាជនចេះតែចេញមក ទ័ពចូលទៅគ្រាន់តែការពារទីក្រុងភ្នំពេញបណ្តោយ ។

សុជាៈ ចុះមានដឹងថាមានមូលហេតុអីបានជាគេជំលាសប្រជាជនចេញមកទេ?

ហឿនៈ ដែលបងបានដឹងគឺមានមូលហេតុ គឺផែនការពីលើមកហ្នឹងគឺខ្លាចប្រជាជនមានបន្កប់ខ្លួនជាទាហានអីណា គេជំលាសប្រជាជនចេញមកគឺដើម្បីបោសសំអាត់នៅក្នុងទីក្រុងអោយអស់ខ្មាំងពីទីក្រុង ។

សុជាៈ ចុះពូដែលមានឋានៈជាប្រធានយោធាវរៈសេនាតូចចឹង តើពូមានដែលបានទទួលបញ្ជារនិងទេ?

ហឿនៈ ដែលបញ្ជារជំលាសហ្ន៎ អានិងបានទទួលបញ្ជារគេមែន ។

សុជាៈ ពូបានទទួលបញ្ជារពីត្រឹមថ្នាក់ណាមក?

ហឿនៈ ត្រឹមថ្នាក់កងពលមក ។

សុជាៈ ពីអឿននិងផ្ទាល់?

ហឿនៈ បា៎! ថាត្រូវតែជំលាសប្រជាជនចេញកុំអោយមានប្រចបូកអីនៅក្នុងទីក្រុង កុំអោយបោសសំអាតខ្មាំងវាអត់ស្អាត តែមកដល់ក្រោយគេមានផែនការអីយ៉ាងម៉េចៗអីបងអត់ដឹងទេ ។

សុជាៈ ជំលាសប៉ុន្មានថ្ងៃបានអស់ពូ?

ហឿនៈ ជំលាសអស់រយះ១ខែជាង ដាក់មួយខែកន្ទះទៅ ។

សុជាៈ ចុះមានដែលប៉ះដូចថានៅមានទាហានលន់ណុលអីគេតដៃតជើងទេ?

ហឿនៈ ទេពេលនេះគ្មានទេ ។

សុជាៈ ចុះបើប្រជាជនអីគាត់មិនចង់ចេញអីវិញតើយ៉ាងម៉េចទៅ?

ហឿនៈ ប្រជាជនដែលមុខសញ្ញាបង ប្រជាជនគឺគ្រាន់តែប្រាប់ថាអោយរៀបចំខោអាវចេញទៅក្រោយទៅ ទៅនៅឯក្រោយទៅពីព្រោះនៅក្នុងទីក្រុងគេមិនអោយនៅទេ បញ្ជារគេនៅខាងលើគេមិនឲ្យនៅ ។

សុជាៈ ចុះមានចូលទៅមានចំវត្តមានលោកសង្ឃលោកអីមានទេ?

ហឿនៈ ដែលបងចូលទៅចូលទៅដែលគេហៅថាវត្តអុណាឡោម វត្តទឹកល្អក់និងវត្តបឹងជប៉ុន ។

សុជាៈ ពេលដែលទៅដល់វត្តអារាមអុិញ្ចឹង តើលោកសង្ឃលោកអីយ៉ាងម៉េចដែរ?

ហឿនៈ អ៊ីទៅដល់វត្តអារាមអត់មានដែលឃើញលោកសង្ឃទេ ។

សុជាៈ លោកចេញអស់ហើយ?

ហឿនៈ លោកនិមន្តចេញអស់ហើយ ។

សុជាៈ អត់មាននៅក្នុងវត្តទេ?

ហឿនៈ អត់មានទេ ទៅវត្តភ្នំជួបព្រះអង្គមួយព្រះអង្គតែគាត់សុគត ។

សុជាៈ សុគតដោយសារអីគេ?

ហឿនៈ សុគតនិងគឺដោយសារលោកជរាពាធទេ នៅក្នុងអាដែងគេហៅថាមរឈូសគេដាក់បារតគេដាក់នៅក្នុងកញ្ចក់អីត្រឹមត្រូវ ។

សុជាៈ មិនមែនគេបាញ់ទេ?

ហឿនៈ បាទ! មិនមែនគេបាញ់ទេ ។

សុជាៈ ហើយចុះដល់ពេលជំលាសប្រជាជនអីហើយ?

ហឿនៈ ជំលាសប្រជាជនហើយរៀបចប់ គេដកបងមកនៅទួលគោក ។

សុជាៈ មកនៅធ្វើអីទៅ?

ហឿនៈ មកនៅឈរជើងនៅអុីទួលគោកហ្នឹង គឺផែនការរបស់វាអោយទ័ពធ្វើស្រែ ។

សុជាៈ ធ្វើស្រែវិញ ចុះធ្វើស្រែនៅកន្លែងណា?

ហឿនៈ ធ្វើនៅទួលគោកវាលក្តួយ ។

សុជាៈ វាលក្តួយនៅកប់ស្រូវហ្នឹង

ហឿនៈ បា! វាលក្តួយនៅកប់ស្រូវ សម្តេចនៅកប់ស្រូវខ្ញុំនៅក្តួយ ។

សុជាៈ ហើយពូនៅនិងភ្នំពេញនិងបានប៉ុន្មានបានគេបញ្ជូនពូមកកប់ស្រូវ?

ហឿនៈ ខ្ញុំនៅបានរយះកាលត្រឹមតែ៣ខែទេ ។

សុជាៈ ចុះអា៣3ខែដែលនៅភ្នំពេញនិងតើគេអោយពូធ្វើអីគេ?

ហឿនៈ នៅគ្រាន់តែដើរបោសសំអាតហ្នឹង ដើរសំអាតនៅតាមផ្ទះបោសតាមទីក្រុងហើយនិងការពារនៅប៉ុសន៍រាជ្យហ្នឹង ។

សុជាៈ ហើយអានិងនៅម៉ុំណាដែរ?

ហឿនៈ នៅនិងវត្តភ្នំហ្នុង ។

សុជាៈ ហើយអឿននិងនៅតែជាមេដដែលទេ?

ហឿនៈ បាំ! នៅតែជាមេខ្ញុំដដែលទេ តែប៉ុលពតចាប់គាត់នៅចុងឆ្នាំ៧៥ ។

សុជាៈ អានិងមុនពូទៅធ្វើស្រូវឬក៏ក្រោយគេបញ្ជូនពូទៅធ្វើស្រូវនៅក្នុយកប់ស្រូវហ្នឹង?

ហឿនៈ នៅរយះក្រោយ ។

សុជាៈ អញ្ចឹងបានន័យថាពេលដែលគេបញ្ជូនពូទៅកប់ស្រូវនមិងគឺអត់មានទោសកំហុសអីទេ?

ហឿនៈ បញ្ជូនទៅនិងគឺនៅក្នុងវរៈទេ ដល់ពេលដែលខ្មែរក្រហមប៉ុលពតនិងគេឡើងកាន់អំណាចពេញសិទ្ធបានពួកវាស្រាវជ្រាវ ស្រាវជ្រាវជាប់បងប្អូនជាប់និងនិការនយោបាយជាប់ច្រពាក់ច្រពិន ហើយអារឿងការងារនយោបាយអាដែងគេហៅថាខ្សែណា ប៉ុលពតគេនិយាយថាខ្សែណាបានគេដកបងទៅខាងសម្ថភាព ។

សុជាៈ ទៅខាងសមត្ថភាព!

ហឿនៈ សមត្ថភាពគឺចូលទៅខាងសន្តិសុខ សន្តិសុខនិងគេយកបងទៅឈដើងនៅព្រែកក្អោយើងនេះ ។

សុជាៈ អញ្ចឹងពេលដែលគេដកមកធ្វើស្រែនៅកប់ស្រូវនេះ អានិងមូលហេតុអីដែរ?

ហឿនៈ ដែលនៅធ្វើស្រែនិងគឺដកនៅក្នុងអង្គភាពទាំងមូលទេ គេអត់ទាន់ស្រាវជ្រាវជាប់និងនិននិរការអីផ្សេងៗអីណាមួយនោះទេ ដល់ក្រោយពេលនោះមកបានដកបងទៅហ្នឹង យើងវាជាប់ខ្សែនិងពួកសេអ៊ីអា កាសេបេរបស់សូវៀតណា ដែលជាប់អាដែងដែលហៅថាប្រធានវរៈសេនាតូជហ្នឹងជាប់និងជាមួយអឿនហ្នឹង គេចោទថាបងជាប់និងខ្សែក្បត់ ដល់គេស្រាវជ្រាវអឿននិងជាអ្នកបំពាក់បំប៉នមកអោយពូ បានទទួលគោលជំហរបានបំពាក់បំប៉នគោលជំហរសតិអារម្មណ៍អ្វីៗទាំងអស់ អញ្ចឹងវាចោទថាបើអឿនក្បត់បងក៏ក្បត់ដែរ ពីព្រោះបងនៅក្រោមបញ្ជារបស់អឿន ។

សុជាៈ ហើយនៅធ្វើស្រែបានប៉ុន្មានបានគេចាប់អឿន?

ហឿនៈ នៅកប់ស្រូវនិងឯងរយះ១ឆ្នាំ ។

សុជាៈ នៅឆ្នាំណាដែរ?

ហឿនៈ ក្នុងរយះកាលឆ្នាំ៧៥និងណា ។

សុជាៈ អញ្ចឹងចូល៧៦ហើយ?

ហឿនៈ ចាំ! ឆ្នាំ៧៥-៧៦ហ្នឹង ដាច់៧៥ចូល៧៦បានគេបញ្ជូនអោយទៅកំពង់ឆ្នាំង ។

សុជាៈ ចុះអាបញ្ជូនមកព្រែកក្អែនេះនោះ?

ហឿនៈ ព្រែកក្អែនៅក្នុងឆ្នាំ៧៥និងវានៅក្នុងរយះនិង ដាច់ឆ្នាំ៧៥ចាប់អឿនពីបយកទៅដាក់គុកព្រៃសរនៅទួលស្លែងហ្នឹង បានគេដកបងមកនៅព្រែកក្អែក្រោយមកដឹងថាអឿនស្លាប់ហើយបានគេបញ្ជូនបងទៅកំពង់ឆ្នាំ ។

សុជាៈ អញ្ចឹងនៅព្រែកក្អែនិងអត់បានយូរដែរ?

ហឿនៈ នៅអត់បានប៉ុន្មានទេ ។

សុជាៈ បានប៉ុន្មានទៅ?

ហឿនៈ បានរយះប្រហែលជា៣ខែទេ ។

សុជាៈ ហើយទៅកំពង់ឆ្នាំទៀត?

ហឿនៈ ទៅអោយធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំ អ្នកជាប់សមត្ថភាពនិងនិនទិរកានយោបាយគឺយកទៅដាក់នៅនិងកន្លែងនិងហ្នង ហើយអោយធ្វើនិងគ្មានពេលវេលាគ្មានម៉ោងអីសំរាប់ឈប់ទេ ព្រោះយើងវាជាប់និងនិនទិរកានយោបាយក្បត់ណា ។

សុជាៈ ចុះពូដូចជាមានឋានៈខ្ពស់ដែរដល់ពេលគេចាប់មកគេពអត់មានចាប់យកទៅដាក់គុកដាក់អី?

ហឿនៈ អត់ទេ អត់បានជាប់គុកទេគ្រាន់តែជាប់និងសមត្ថភាពដែលគេតាមដាន តែគេយកយើងទៅដាក់នៅត្រង់និងគឺនៅក្នុងសភាពតាមដាន បើយើងមិនកសាងខ្លួនគឺទៅហើយខុសតែមួយវិនាទីក៏គេចាប់ដែរ ព្រោះគេផ្ទួរទោសបើសម័យយើងឥឡូនេះដូចគេផ្ទួរទោសរួចស្រេចហើយ គេចាប់ម៉ោងណាក៏បានពេលវេលាណាក៏បានអោយតែយើងប្រព្រិត្តបទល្មើសខុសជំហានបន្តិច គឺគេចាប់ហើយ ។

សុជាៈ ចុះរឿងបងមួយឈ្មោះចេសនោះ?

ហឿនៈ បងខ្ញុំគឺខ្ញុំដឹងខ្សែរឿងគឺនៅពេលរំដោះរួចហើយ ខ្ញុំបានទៅជួបជាមួយបងណា ជួបជាមួយបងខ្ញុំបានផ្តាំផ្ញើរជាមួយបងដែរថា យើងត្រូវប្រយ័ត្នខ្លួនព្រោះយើងវានៅក្នុងកណ្តាប់ដៃរបស់ប៉ុលពតហើយសភាពការណ៍វាអត់ស្រួលទេវាប្រែប្រួលហើយ អញ្ចឹងតាមខ្ញុំដែលសារសោចផ្សាឈាមអីទៅជួបរាល់ថ្ងៃគឺអត់បានទេ គឺបានឈ្លាតទៅជួបបានគ្នាអស់រយះកាលមិនដល់មួយម៉ោងផង ។

សុជាៈ ជួបគ្នានៅពេល៧៥ហ្នឹង?

ហឿនៈ បាទនៅឆ្នាំ៧៥ហ្នឹង អញ្ចឹងបងខ្ញុំដែលហៅថានៅក្នុងកំឡុងខ្មែរក្រហមនិងគាត់ពីដើមគាត់ធ្វើការគឺថាគាត់ធ្វើការបំរើសង្គមពីដើម ហើយគេស្រាវជ្រាវគាត់គឺវានៅសេសសល់ដល់គេស្រាវជ្រាវទៅគេចាប់យកគាត់ទៅសំលាប់បណ្តោយ ។

សុជាៈ ពូដឹងថាគេយកទៅសំលាប់ដែរ?

ហឿនៈ បាទដែលក្នុងយេះដែលគេចេញទៅចាប់នោះ គឺពូអត់ទាន់បានដឹងទេគឺប្រហែលជារយះ១ខែ២ខែមានគេលួចខ្សឹបប្រាប់ថា នែបងបង្កើតរបស់បងឯងគឺគេចាប់ទៅហើយ ។

សុជាៈ គាត់ធ្វើអីគេកាលហ្នឹង?

ហឿនៈ គាត់នៅធ្វើប្រធានកងតូច ដល់ពេលរំដោះយើងគេរំសាយហើយៗនិង គាត់ទទួលជាប្រធានកងតូចនៅខាងពាណិជ្ជកម្ម ។

សុជាៈ នៅក្រសួងពាណិជ្ជកម្ម?

ហឿនៈ បាទនៅខាងដឹកជញ្ជូន ។

សុជាៈ នៅរហូតដល់ពេលណាដែរ?

ហឿនៈ ទៅរហូតដល់ពេលដែលយើងផ្ទុះនៅជាយដែន ដែលយើងសម្តេចទៅពឹងផ្អែកវៀតណាមមករំដោះហ្នឹង ។

សុជាៈ នៅឆ្នាំណាអាហ្នឹង?

ហឿនៈ នៅឆ្នាំ១៩៧៩បង ។

សុជាៈ ៧៩បែកហើយនិងបង?

ហឿនៈ ទេដែលផ្ទុះនិង......

សុជាៈ តើពូនៅកំពង់ឆ្នាំបានប៉ុន្មាន

ហឿនៈ នៅកំពង់ឆ្នាំងបាន១ឆ្នាំ ។

សុជាៈ ១ឆ្នាំ ពូនៅ៧៦-៧៧ នៅដល់ចុងឆ្នាំ៧៧?

ហឿនៈ បាទដល់ចុងឆ្នាំ៧៧ហើយ វាវគ្គអស់ហើយព្រោះវាយូរពេក ។

សុជាៈ អានិងគេធ្វើម៉េចវចវិញ?

ហឿនៈ ដលពេលតេផ្ទុះហើយ គេប្រាប់ថារំសាយទោស បាំ!រំសាយទោសគេយកយើងមកបំពាក់បំប៉នវិញ ព្រោះយើងធ្លាប់មានស្នាដៃធ្លាប់ប្រយុទ្ធជាមួយទាហានជាមួយខ្មាំង អញ្ចឹងយកយើងមកបំពាក់គោលជំហរនយោបាយអោយរឹងប៉ឹងគោលជំហរវៃឃ្លូន ។

សុជាៈ ចុះបើកាលនិងបើយើងអត់ទៅវៃយួន គេបង្ខំឬក៏គេដាច់ខាតអោយយើងទៅ?

ហឿនៈ ទេគឺដាច់ខាតត្រូវតែទៅតែម្តង ព្រោះវានៅក្នុងចង្កោមរបស់វាដែរគឺគេគ្រាន់តែរំសាយទេ ដូចថាយើងត្រូវមានទោសត្រូវសំលាប់ គេលើកលែងទោសយើងឈប់សំលាប់គេយកយើងមកឲ្យទៅបំពាក់បំប៉នអោយយើងទៅវៃជាមួយយួនវិញ ។

សុជាៈ ទៅវៃយួនដល់ឆ្នាំណាទៅ?

ហឿនៈ ទៅវៃយួននៅក្នុងឆ្នាំ៧៨ហ្នឹង ។

សុជាៈ ទៅក្នុងខេត្តណាដែរ?

ហឿនៈ គេយកបងទៅនិងយួនគេហៅខេត្តតាយណិញ ។

សុជាៈ ចុះនៅខាងខ្មែរ?

ហឿនៈ ខ្មែរបងវៃនៅអមលាំង ។

សុជាៈ អមលាំងបងវៃនៅជិតភ្នំពេញណោះវិញ?

ហឿនៈ បាទ!នៅខាងជើងភ្នំពេញនៅជិតវ៉ារទេះភ្លើង អមលាំងនៅខាងពោសាត់នេះ ។

សុជាៈ ចុះពេលទៅវៃនៅខាងតាយណិញ?

ហឿនៈ តាយណិញគឺគ្រាន់ទៅដល់វៃពិប វៃបានប្រហែលជាមួយអាទិត្យនៅក្នុងនិងណាវៃជាមួយយួននៅហ្នឹង ហើយយួនចូលទៅដល់ភ្នំពេញបាត់ មកដល់ភ្នំពេញអត់បានធ្វើអីទេបែកគ្នាអស់នាំគ្នាជិះរត់គ្រោះរត់មកណោះវិញ ។

សុជាៈ មកអមលាំងវិញ?

ហឿនៈ បាទ! ឆ្លងទន្លេបិតនេះ ។

សុជាៈ អញ្ចឹងទៅបានតែមួយអាទិត្យ?

ហឿនៈ មួយអាទិត្យទេ អមលាំង ។

សុជាៈ អញ្ចឹងចុង៧៨ហើយមិនមែន៧៧ទេ?

ហឿនៈ បាទ! ចុង៧៨ហើយ ។

សុជាៈ រួចហើយបានដកមក....?

ហឿនៈ មកខាងលាច លាចខាងវ៉ាំម៉ាណក់ខាងពោសាត់ ។

សុជាៈ ចុះពេលណាដែលពូត្រឡប់មកដល់ផ្ទះនេះវិញ?

ហឿនៈ មកដល់រយះចុងឆ្នាំ៧៨និងគេបញ្ជូនបងរហូតជិតទៅដល់ថៃ ដល់ពេលនេះទៅបងបានដឹងសភាពការណ៍វា ហៅថាវាមិនមែនពិតជារឿងការតស៊ូយើងវាមិនបានការ បងត្រឡប់មកវិញបងរួមរស់ជាមួយរដ្ឋាភិបាលយើងសព្វថ្ងៃ នាំកំលាំងនារី៣០នាក់ហើយនិងកំលាំងយុវជន៥៦នាក់ និងមានតេអូ៣គ្រឿង អាវុធគ្រប់ដៃបងមានកាំភ្លើងខ្លីមួយដេមតេអូ១គ្រឿងយកជូនរាជរដ្ឋាភិបាល

សុជាៈ ពូចូលមកចំខេត្តណា?

ហឿនៈ ចូលមកនៅខេត្តបាត់ដំបង ស្រុកពពរខេត្តពោសាត់ ។

សុជាៈ ចុះពេលចូលមកអញ្ចឹងរដ្ឋអំណាចគេបញ្ជូនយើងមកភូមិទេ?

ហឿនៈ មកដល់និងខ្ញុំប្រគល់សំភារៈអ្វីជូនរដ្ឋអំណាចអស់ គេទុកអោយបងនៅហ្នឹងដើម្បីបំពាក់បំប៉ន់ផ្នែកនយោបាយណា ហើយធ្វើការនៅនិងអស់រយះកាល១ឆ្នាំ ។

សុជាៈ មកដល់ណោះឆ្នាំ៨០អី?

ហឿនៈ បាទ៨០ហើយ អញ្ចឹងដល់ពេលបងធ្វើការនៅនិងហើយក៏បង ដូចថាវាបែកម្តាយយូរពេកមិនដឹងជាបងប្អូននិងស្លាប់ប៉ុន្មានមិនដឹងជាម្តាយនិងគាត់ស្លាប់ឬក៏រស់ សុំខាងរដ្ឋអំណាចនិងមកថាមកមើលម៉ែមើលឪទេបងត្រឡប់ទៅវិញទេ ទទួលជាមកម្តាយនិងគាត់ក៏មានជំងឺជពាធទៅបងក៏អត់អាចវិលត្រឡប់ទៅវិញអត់រួច ហើយក៏វាដាច់ខ្សែរយះត្រឹមនិងទៅ ។

សុជាៈ ចុះពូខ្ញុំសួរបកទៅមុខនេះបន្តិចវិញ ពេលដែលពូចូលទៅដល់ភ្នំពេញភ្លាមនិងគេមានអោយពូទៅរៀននយោបាយនិងទៅធ្វើមេទិញអីតើមានទេ?

ហឿនៈ មាន ។

សុជាៈ ទៅធ្វើមេទិញនៅឯណា?

ហឿនៈ ទៅកន្លែងរៀនដែលថាកន្លែងរៀននយោបាយនិងគឺនៅស្តាតអូឡាំពិក ។

សុជាៈ កាលនិងទាហានប្រជាជនមកពីខាងណាខ្លះទៅ?

ហឿនៈ មកគ្រប់ខេត្តចាប់ពីវរៈសេនាតូច វរៈសេនាធំ អនុកងពល ។

សុជាៈ អានិងយុទ្ធជនអត់សួរមានទេ?

ហឿនៈ យុទ្ធជនអត់មានរៀនជាមួយនិងអ្នកធំៗបានទេ ។

សុជាៈ អ្នកណាដែលមកបង្រៀនមកធ្វើមេទិញហ្នឹង?

ហឿនៈ ន៎ែ.....ខាងមជ្ឈិមខាងអី ឈ្មោះ.......ឈប់សិនរកនឹងសិនដូចភ្លេចហើយ.....ខាងណាទេអូរឈ្មោះខៀវគេហៅតាខៀវៗ ។

សុជាៈ ដែលគេហៅតាខៀវៗហ្នឹង?

ហឿនៈ បាទ! ។

សុជាៈ អានិងឈ្មោះគាត់ ចុះមានដឹងថាឈ្មោះពិតរបស់គាត់ឈ្មោះអីទេ?

ហឿនៈ ទេអត់មានដឹងទេ ។

សុជាៈ គាត់មានតួនាទីជាស្អីដែរ?

ហឿនៈ តួនាទីគាត់និងបើនិយាយទៅគាត់គេហៅតែគណៈប្រទេសៗ ។

សុជាៈ គាត់បង្រៀនប៉ុន្មានថ្ងៃ?

ហឿនៈ រៀនចាប់ពីមួយអាទិត្យទៅកន្លះខែ ។

សុជាៈ រៀននៅឯណាដែរ?

ហឿនៈ រៀននៅស្ពានអូរឡាំពិក ។

សុជាៈ ហើយក្រៅពីតាខៀវនិងមានពីណាទៀតទេ?

ហឿនៈ តាមសមាជិកឈ្មោះប្រជិតៗចុងមាត់.....នៅតែឃើញមុខគាត់និងតែភ្លេចឈ្មោះ គាត់នៅខាង អគ្គៈរដ្ឋទូតខាងក្រសួងក្រៅប្រទេស.......... ។

សុជាៈ គាត់និងគាត់ជាទាហានដែលឬក៏ស៊ីវិល?

ហឿនៈ គេមេ....ប្អូនថ្លៃតាខៀវសំផននេះ បងថ្លៃអិញ្ចេះ ។

សុជាៈ ឈ្មោះអីគេទៅ?

ហឿនៈ ឈប់រកនឹកសិន ។

សុជាៈ កាលនិងគាត់មកបង្រៀននយោបាយ?

ហឿនៈ បាទ! ។

សុជាៈ គាត់មកបង្រៀនដែរ?

ហឿនៈ បាទ! ។

សុជាៈ គាត់និយាយពីអីគេទៅ?

ហឿនៈ និយាយពីបញ្ហាគោលនយោបាយគេ ដូចថាយើងដឹកនាំប្រទេសជាតិពង្រឹងគោលជំហរ ហើយនិង ស្រាវជ្រាវអ្នកដែលមានសមភាព ដែលគេហៅថាជាប់និន្ននិរការនយោបាយណា ។

សុជាៈ និន្ននិរការនយោបាយយ៉ាងម៉េច គេស្រាវជ្រាវយ៉ាងម៉េច?

ហឿនៈ និន្ននិរការនយោបាយពីដើមដូចជាមាន បងជាប់ធ្វើជាទាហាន ធ្វើរាជការពីសង្គម ។

សុជាៈ ចុះបើគេស្រាវជ្រាវឃើញ គេយកទៅធ្វើម៉េច?

ហឿនៈ បើគេឃើញគេដកចេញអត់អោយជាប់ទេ ។

សុជាៈ ចុះគេដកចេញតើដកយកទៅណាវិញ?

ហឿនៈ អានិងគេដក តែដកគឺជាប់គុកព្រៃសរហើយ អោយតែជាប់និងនិននិរកានយោបាយពីដើម ដែលជាប់និងឥទ្ធិពលពីសង្គមចាស់ជំនាន់សម្ដេចហ្នឹង ។

សុជាៈ ចុះដល់ពេលចូលគុកព្រៃសរទៅ គេធ្វើទារុណកម្មក៏សម្លាប់ដែរអត់?

ហឿនៈ ទេអាត្រង់ទៅនិងបងអត់ដឹងទេ ទារុណកម្មវាមិននេះទេព្រោះវាយកទៅដាក់ច្រវាក់ដាក់ខ្នោះហើយ

សុជាៈ ហើយមូលហេតុអីបានជាពូដឹងថាគេយកទៅដាក់ព្រៃសរ?

ហឿនៈ មូលហេតុត្រង់ថាគេយកទៅដាកព្រៃសរ ព្រោះយើងជាប់និងនិននិរកានយោបាយនិងវាទោសធ្ងន់

សុជាៈ ចុះព្រៃសរនិងពូដឹងថាដាកន្លែងសំរាប់អ្នកទោសកាលពីជំនាន់និងអញ្ចឹងហ្នងកាលពីជំនាន់ហ្នឹង?

ហឿនៈ បាទ! ។

សុជាៈ ចុះបើសិនជាយើងទោសស្រាលវិញ តើគេយកទៅដាក់នៅឯណាទៅ?

ហឿនៈ យើងទោសកំរិតស្រាលគេយកយើងទៅដាក់នៅកន្លែងកសាងវា កន្លែងកសាងនិងវាយកទៅដាក់មួយដុំគេហៅភូមិបែកត្រឡោកទួលគោកយើងនេះ ។

សុជាៈ នៅត្រឡោកបែកទួលគោក?

ហឿនៈ បាទ!..នៅត្រឡោកបែក វាអោយបាអាកំប្លោកយើងខាងលិចត្រឡោកបែកនិងមួយដួរទួលគោក ។

សុជាៈ ចុះអាទោសស្រាលទោសធ្ងន់និងវាយ៉ាងម៉េច?

ហឿនៈ ទោសស្រាលអានិងនៅកំរិតហ្នឹង បើទោសធ្ងន់វាយកទៅដាក់នៅកន្លែងនៅស្ពានតាមោកយើង ។

សុជាៈ ស្ពានតាមោកនិងនៅឯណាដែរ?

ហឿនៈ នេះនៅព្រែកតាមាក់យើងនេះដែលគេហៅថាស្ពានតាមោកៗ អាថ្មលំទៅ..។

សុជាៈ តែអ្នកយ៉ាងមេចដែលគេគំណត់ថាទោសស្រាល ហើយអ្នកយ៉ាងម៉េចដែលគេកំណត់ថាអ្នកនោះមានទោសធ្ងន់?

ហឿនៈ វាគណត់ថាដូចថាយើងជាប់និងនិននិរកាតិចតួចអានិងមានទោសស្រាល បើយើងជាប់និននិរកាដែលមានទោសធ្ងន់ ជាប់និងទោសធ្ងន់គឺជាប់និងនិននិរកានយោបាយក្បត់ បាទ!អានិងធ្ងន់ហើយដូចថាអូនឯងនិងពូជាជីដូនមួយនិងគ្នាបង្កើត តែគេចាប់ពូហើយក្មួយឯងក៏ក្បត់ដែរ ។

សុជាៈ ចុះតាអីដែលពូថាតាខៀវហើយតាអី....អៀងសារី?

ហឿនៈ អៀងសារីនិងហើយ អូនឯងទើបតែនិងនឹកឃើញអៀងសារីនោះឯង ។
សុជាៈ ចុះអៀងសារីនិងនៅឯណាដែរ គាត់ធ្វើការនៅខាងអី?
ហឿនៈ គាត់នៅខាងកាលនិងគាត់នៅជាប់ជាមួយនិងប៉ុលពតហ្នឹង ដែលជាសមាជិកដែលគេហៅថាសាខា នៅក្នុងមួយចង្កោមគេនិង គេកាន់ជាប្រធានអនុប្រធាន ។
សុជាៈ ចុះគាត់កាន់នៅខាងផ្នែកអីគេ?
ហឿនៈ កាន់ខាងផ្នែកនយោបាយ ។
សុជាៈ គាត់មកបង្រៀនឃោសនា?
ហឿនៈ គាត់មកអូរឡាំពិកដូចថាគាត់ជាប្រធាននយោបាយ ប្រធានសាលានយោបាយខាងបំពាក់បំប៉ន ។
សុជាៈ គាត់មកមាននិយាយពីរឿងអាខ្មែរក្បត់ខ្មែរអីទេ?
ហឿនៈ បាទ!..បងប្អូនជាប់និងខ្មែរក្បត់បងប្អូនជាប់និងនិននិរកានយោបាយ បងប្អូនជាប់និងននិរកាសង្គម ចាស់ ចឹងទោះបីជាយើងជាប់និងថ្នាក់ណាក៏ដោយក៏គេដកចេញដែរ ។
សុជាៈ អៀងសារីជាអ្នកនិយាយអញ្ចឹងហ្មង?
ហឿនៈ បាទ! ។
សុជាៈ រៀនជាមួយគាខៀវនិងបានរយៈពេលប៉ុន្មាន?
ហឿនៈ ខ្ញុំរៀនច្រើនដែរ ប្រហែលជា៣-៤.....៥វគ្គដែរ ។
សុជាៈ ញឹកញាប់ដែរជាមួយអៀងសារីដែរ?
ហឿនៈ ជួនកាល២ខែឬ១ខែគេហៅទៅបំពាក់បំប៉នមួយដង ដែលគេហៅថាសន្និបាតនៅក្នុង១-២ខែគេ ហៅទៅសន្និបាតមួយដង គេមិនមែនហៅទៅរៀនទេគឺគេហៅទៅសន្និបាតកាលពីសម័យប៉ុល ពត នោះ ។
សុជាៈ តែត្រឹមថ្នាក់ណាទៅដែលអាចចូលទៅក្នុងនោះ?
ហឿនៈ ត្រឹមថាអ្នកដែលចូលទៅសន្និបាតនៅស្តាតហ្នឹងមានត្រឹមតែអនុសេនាធំ ប្រធានវរៈសេនាតូច ។
សុជាៈ កាលនិងគេមិនទាន់ចាប់អឿនទេ?
ហឿនៈ បាទគេមិនទាន់ចាប់អឿនទេ ។
សុជាៈ កាលនិងពូនៅប្រធានវរៈសេនាតូច?
ហឿនៈ បាទនៅប្រធានវរៈសេនាតូច ។
សុជាៈ ពីណាគេប្រធានលើវរៈសេនាធំ?

ហឿនៈ ប្រធានវរៈសេនាធំឈ្មោះផេង ។

សុជាៈ ហើយអឿននិងឡើងទៅគឺអឿននិងហ្នឹង ។

ហឿនៈ ចាំ!....ប្រធានវរៈសេនាធំផេង ដល់ប្រធានកងពលគឺតាអឿននិងហ្នឹង ។

សុជាៈ ចុះពីណាគេជាអនុប្រធានពូ?

ហឿនៈ ឈ្មោះជឹម អនុប្រធានឈ្មោះជឹមគាត់ស្លាប់ទៅហើយ ។

សុជាៈ ស្លាប់ដោយសារមូលហេតុអី?

ហឿនៈ មូលហេតុដោយសារប៉ុលពតចាប់ ។

សុជាៈ ចុះពូមូលហេតុអីបានជាគេអត់ចាប់?

ហឿនៈ គេអត់ចាប់គឺដោយសារជាប់និងនិន្នាការនយោបាយ គេយកទៅដាក់នៅកន្លែងកសាងខ្លួនហ្នឹង ពីព្រោះពូអត់ជាប់ច្រពាក់ច្រពិនផ្នែកនយោបាយទេ ច្រពាក់ព្រិនតែនិងជាមួយអឿននិងបន្តិចទេ ។

សុជាៈ អញ្ចឹងនយោបាយម៉េចទៅដែលពូអត់ជាប់ច្រពាក់ច្រព័ន្ធជាមួយហ្នឹង?

ហឿនៈ ដែលអត់ជាប់ពាក់ព័ន្ធព្រោះអត់មានខ្សែបងប្អូនណាក្បត់ ក៏បងនិងមានបងជាប់និងខ្សែក្បត់អញ្ចឹងទៅក៏បងជាប់និងខ្សែក្បត់និងនិន្នាការនយោបាយនិងដែរ ។

សុជាៈ ចុះតាខៀវនោះគាត់មាននិយាយពីរឿងអីខ្លះ?

ហឿនៈ តាខៀវគាត់និយាយតែពីរឿងពង្រឹងនយោបាយគោលជំហរ កុំអោយមានកំហុសអោយខិតខំនាំគ្នាកសាងខ្លួន កុំអោយចាញ់បោកគោលជំហរនយោបាយណាមួយដែលមកបោកប្រាសយើងឲ្យជឿដែលគេហៅថាផ្នែកណាមួយ បើមាននិន្នាការណាមួយមកទាក់ទាញចូលទៅគឺកុំអោយចូលទៅកុំអោយចូលទៅបំរើកាសេបេ សេអ៊ីអាចូលស៊ើស្រាប់តែវាលើកឡើងទៅ ហើយរួចយើងគឺចេះតែស្លាប់បើយើងអត់ដឹងដែរ ។

សុជាៈ ហើយកាលនិងតាខៀវអីនិងគាត់មានធ្លាប់និយាយពីរឿងកាសេបេនិងសេអ៊ីអាអីទេ?

ហឿនៈ ចាំ! ។

សុជាៈ និយាយថាម៉េចខ្លះកាសេបេ សេអ៊ីអាហ្នឹង?

ហឿនៈ បើកាសេបេគឺធ្វើជាគិញសំងាត់អោយសូវៀត ។

សុជាៈ ចុះសេអ៊ីអា?

ហឿនៈ សេអ៊ីអាខ្ញុំអត់ដឹងដែរមិនដឹងជាគេថាម៉េចបើពាក្យវាអញ្ចឹង ។

សុជា៖ ចុះមានពីណាម្នាក់ដែលគេចាប់ដោយមូលហេតុជាប់ខ្សែកាសេបេឬក៏ សេអ៊ីអា ឬក៏ជាប់និងបងប្អូនដែលធ្វើការធំធ្វើអី?

ហឿន៖ ជាប់ច្រើនណាស់ដែលវាជាប់ ដូចប្អូនឯងហើយនិងបងដែលកំពុងតែបំរើ ដូចថាធ្វើការទាំងយប់ទាំងថ្ងៃអញ្ចឹង ឡានមកដល់ឈឺបដូចឡានមកម៉ិញអញ្ចឹង ដល់វាមកវាចាប់បងមួយឬប្អូនឯងមួយទៅហើយវាដាក់ខ្សែភ្លើង ហើយចោទថាមើលឯងឆ្លើយមើល តើឯងបំរើអោយសេអ៊ីអានិងកាសេបេតាំងពីឆ្នាំណា រួចយើងអត់ដែលស្គាល់សេអ៊ីអាកាសេបេផងមិនដឹងជាឆ្លើយថាម៉េច ដល់ពេលវាធ្វើទារុណកម្មចំពោះប្អូនឯងឬបងខ្លាំង ហើយចុះបើក្នុង១ថ្ងៃឆក់ខ្សែភ្លើង៤-៥ដង រួចប្អូនឯងទ្រាំមិនឆ្លើយម៉េច ថាតាំងពីឆ្នាំប៉ុននេះមកតាំងពីឆ្នាំ៧៣តាំងពីឆ្នាំ៧៤មក រួចប្អូនឯងមិនឆ្លើយម៉េចបើតាកាប់ដកកញ្ចកជើងកញ្ចកអី ។

សុជា៖ ពូដែលឃើញទេ ពូដឹង?

ហឿន៖ ដឹងពិតតែហ្នឹង ។

សុជា៖ ឃើញនៅកន្លែងណាទៅ?

ហឿន៖ ឃើញនៅកន្លែងសន្តិសុខវាដាក់នៅកន្លែងខាងជើងវត្តភ្នំនៅអែបនិងមាត់ទន្លេ នៅជាប់និងស្ពានជ្រោយចង្វារ ១ថ្ងៃឆក់ពី៣-៧ដងអានិងខាងពួកតំបន់គេដាក់នៅត្រង់ហ្នឹង ពួកតំបន់ពួកគណៈស្រុក ។

សុជា៖ គេចាប់ពីនេះទៅ?

ហឿន៖ បាទគេចាប់ពីលើទៅ បើផ្នែកទ័ពគេចាប់អត់មានទុកនៅនេះទៅគឺបញ្ជូនទៅព្រៃសរ គេយកទៅវៃចោលបណ្តោយ បើពួកតំបន់ពួកគណៈស្រុកនៅនិងតែហ្នឹងផ្ទះនៅនិងសព្វថ្ងៃបងទៅឃើញ កាលមុនបងយកកូនទៅដេកពេទ្យនៅឃើញ ។

សុជា៖ នៅខាងណាពេទ្យ?

ហឿន៖ នៅខាងផ្លូវពេទ្យនេះ អាយើងទៅពីខាងត្បូងស្តាតចាស់ទៅនេះគេហៅពេទ្យអី ។

សុជា៖ ពេទ្យកុមារមជ្ឈឹម ពេទ្យគន្ធះបុប្ផា!

ហឿន៖ ពេទ្យគន្ធះបុប្ផាអីពេទ្យកាល់ម៉ែតយើងនេះ នៅខាងត្បូងពេទ្យកាល់ម៉ែត អោយបងទៅប្រាប់បងទៅចង្អុលបាច់ៗផ្ទះនោះ ។

សុជា៖ កន្លែងនិងគេធ្វើជាស្អីគេ?

ហឿន៖ អានិងកន្លែងសន្តិសុខរបស់វាហើយហ្នឹង ។

សុជាៈ សន្តិសុខរបស់ពីណាគេ?

ហឿនៈ បោះខាងមជ្ឈិមហ្នឹង ។

សុជាៈ របស់ខាងភូមិភាគខាងឧត្តរហ្នឹង?

ហឿនៈ ចា៎!... អត់ទេគេដាក់មជ្ឈិមនិងគឺគេជាសន្តិសុខខាងមជ្ឈិមហ្នុង ។

សុជាៈ ពីណាគេជាអ្នកគ្រប់គ្រង?

ហឿនៈ ដូចថាគណៈស្រុកដែលគេចាប់ពីសៀមរាប ពីកំពង់ចាមចាប់ពីអាដែងយើងខាងនោះ នៅក្នុងខេត្ត និងតែម្តង អោយតែនៅខាងឧត្តរនិងគេដាក់នៅកន្លែងនិងតែម្តង ។

សុជាៈ ពីណាគេជាអ្នកគ្រប់គ្រងនៅកន្លែងហ្នឹង?

ហឿនៈ បងអត់ស្គាល់ឈ្មោះទេ ។

សុជាៈ ចុះម៉េចបានជាពូអាចទៅមើលបាន?

ហឿនៈ បងគឺដាក់ស្តែងគឺកន្លែងបងនៅជិតនិង ហើយលបមើលមានតាំងពីកូនតូចកូនតាំងពីប៉ុប៉ុនហ្នឹងយំទ្រហឹងអើងកង អោយតែស្មើនេះវាវៃមួយសារហើយដួងដាំង១ទៅ អាណាឆ្លើយក៏ឆ្លើយទៅអាណាមិនឆ្លើយក៏ឆក់ខ្សែភ្លើង អានិងជាការពិតណាមិនមែនយកនិយាយរឿងនិងមកនិយាយលេងទេគឺបងបានឃើញពិត បងនិយាយហ៊ានសច្ចារថ្ងៃប៉ុប៉ុនណេះបើសិនជាបងនិយាយមិនពិត គឺបងអត់និយាយទេ អានេះជាឃាតកររបស់ប៉ុលពតណា៎ ដែលបងឃើញដាក់ស្តែងហើយក៏បងមិនដែលបានធ្លាក់ដល់កំរិតនិងដែរទោសបង គ្រាន់តែចូលដល់កំឡុងកសាងពង្រឹងគោលជំហរខ្លួនឯងដើម្បីកសាង តែបើកសាងមិនបានទេគឺនៅពេលនិងហើយ ។

សុជាៈ ពូឃើញនិងឃើញចំងាយប៉ុន្មានដែរពីកន្លែងដែលធ្វើទារុណកម្មហ្នឹង?

ហឿនៈ ចំងាយមិនដល់ជា៥០ម៉ែត្រផងព្រោះរបងផ្ទះនៅទីក្រុងភ្នំពេញ ផ្ទះនៅពេញដែលឆ្ងាយពីគ្នាហ្នុ៎ផ្ទះនៅពេញ ។

សុជាៈ នៅក្នុងផ្ទះថ្ម?

ហឿនៈ បាទនៅក្នុងផ្ទះថ្ម រួចខ្ញុំនៅផ្ទះថ្មដែរខ្ញុំនៅអាថ្នាក់ពីជាន់ហើយខ្ញុំមើលទៅឃើញ ព្រោះផ្ទះគេកញ្ចក់ ។

សុជាៈ ចុះពីណាគេជាអ្នកធ្វើទារុណកម្ម?

ហឿនៈ បងអត់ទទួលស្គាល់ទេ បងអត់ស្គាល់ទេព្រោះបងមិនហ៊ានសួរ មិនហ៊ានសួរថាគេចាប់មកពីណាហើយថ្នាក់ណាទៅកាន់មន្ទីរសន្តិសុខ កសាងខ្លួនមនហ៊ានកំរើកទេអូននិយាយពីខ្លួនរឹងជាស្អីទៀត ។

សុជាៈ ចុះកាលនិងគេចាប់អឿនទៅ?

ហឿនៈ កាលនិងគេចាប់ហើយ ។

សុជាៈ កាលដែលពូយើញគេធ្វើទារុណកម្មហ្នឹង?

ហឿនៈ វាអិញ្ចេះផ្ទះសន្តិសុខនិងវានៅជាប់គ្នាអិញ្ចេះ ដល់គេចាប់អឿនទៅគេយកកន្លែងអឿននិងធ្វើជាកន្លែងសន្តិសុខ ។

សុជាៈ ចុះពូគេដកមកលតដំនៅកន្លែងណាវិញ?

ហឿនៈ អានិងគេអត់ទាន់ដកទេនិងកន្លែងនិងដដែល ដល់ពេលគេដកបងមកនៅទទួលគោកមកកសាងខ្ទនៅទទួលគោកហ្នឹង អានិងដំណាក់កាលដែលក្រោយមកបងអត់ដឹងថាគេប្រែប្រួលយ៉ាងម៉េចទេ ។

សុជាៈ ពេលដែលពូធ្វើជាអ្នកបោសសំអាតក្រុងអីនៅម្តុំវត្តភ្នំអីហ្នឹង?

ហឿនៈ បាទនៅម្តុំវត្តភ្នំហ្នឹង ។

សុជាៈ ពូយើញញឹកញាប់ទេការធ្វើទារុណកម្មហ្នឹង?

ហឿនៈ ចុះបើនៅនិងអស់រយះ១ខែ២ខែឃើញរាល់តែថ្ងៃ ជួនកាលស្ទើនិងឃើញឡានគេទៅហើយឡានទៅពីតំបន់យើងហ្នឹង ទៅហើយទៅពីតំបន់និងទៅហើយចូលផ្ទុក ។

សុជាៈ ហើយគេចាប់គណៈតំបន់?

ហឿនៈ គេចាប់គណៈតំបន់ គណៈស្រុកប្រធានសង្កាត់ ។

សុជាៈ ពូឃើញមានស្គាល់ពីណាគេមួយទេ?

ហឿនៈ ខ្ញុំស្គាល់តែម្នាក់ទេឈ្មោះអ៊ឹចនមួយ ។

សុជាៈ គាត់ជាអីគេ?

ហឿនៈ គាត់នៅគណៈស្រុកបារាយណ៍យើងនេះ ។

សុជាៈ ឃើញទៅចូលនៅនិងដែរ?

ហឿនៈ បាំ! ។

សុជាៈ គាត់មានធ្វើអីខុសទេ បានជាគេចាប់គាត់?

ហឿនៈ ចុះគេចាប់ ស ជឹម គេចាប់ ស ជឹម ទៅហើយគាធុចទៅ ចននិងគាធុចននវាខ្សែរយះជាមួយគ្នា តស៊ូសម័យខ្មែរក្រហមជាមួយគ្នាដល់គេចាប់ ស ជឹម ទៅគាធុចនិងទៅវាមិនជាប់និងនិននិរកានយោបាយ គេបំពាក់បំប៉ន ស ជឹម ហើយនិងធុចហ្នឹង ។

សុជាៈ ចុះធួននិងជាស្អីគេ?

ហឿនៈ គណៈតំបន់ ។

សុជា៖ តំបន់ណា?

ហឿន៖ តំបន់យើងខត្តរនេះ ។

សុជា៖ តំបន់ឬក៏ភូមិភាគ?

ហឿន៖ ភូមិភាគប្រទ្បំតំបន់ ។

សុជា៖ អញ្ចឹងនៅពេលដែលគេចាប់ កុយ ឃួន ចាប់អឿននិងគេចនបណ្តើរៗហើយ?

ហឿន៖ បាទ!..គេចាប់បណ្តើរៗហើយ ។

សុជា៖ ចុះពូហេតុអីយូរម្លេះបានគេចាប់ គេយកទៅលត់ដំព្រោះគេចាប់អឿនបាន២-៣ខែហើយបានគេចាប់ពូ?

ហឿន៖ គេចាប់ទៅ ដល់ពេលដែលគេចាប់សំណួមពរដែលគេយកអឿនទៅចំលើយ ថាបានបំពាក់បំប៉ន ឈ្មោះអីខ្លះៗដែលដឹកនាំនយោបាយបំពាក់បំប៉ន ដូចថាមានឈ្មោះហឿនចុះដល់អញ្ចឹងទៅគេចាប់ផ្តើមស្រាវជ្រាវប្រវត្តិរូបដែលហៅសមភាព គេស្រាវជ្រាវប្រវត្តិរូបថាតើយើងនិងវាមានជាប់និងនិននិរកានយោបាយគិចឬច្រើនវាមានទោសទៅតាមកំរិតហ្នឹង ។

សុជា៖ ចុះនៅក្នុងកំឡុងដែលគេកំពងតែស្រាវជ្រាវនិង តើពូនៅជាប្រធានវរៈសេនាតូចដដែល?

ហឿន៖ នៅវរៈសេនាតូច ។

សុជា៖ ហើយការងារគេអោយធ្វើអីគេ?

ហឿន៖ ការងារនៅនិងគឺអត់មានធ្វើអីទេ ។

សុជា៖ ដើរយាមទៅ?

ហឿន៖ បាទ! ដើរយាមហើយគ្រាន់តែដើរមើលកូនទាហានទៅ ហើយនិងដើរបោសសំអាតនៅតាមថ្នល់ ។

សុជា៖ ចុះថាគុកដែលគេចាប់មនុស្សឃុំនៅហ្នឹង តើពីណាគេជាអ្នកកាន់កាប់តើនៅក្នុងអគ្គភាពរបស់លោកពូដែលឬក៏មកពីខាងគេផ្សេង?

ហឿន៖ បាទ! គេយកមកពីដែលហៅថានិរតី ។

សុជា៖ យកពីនិរតីមកវិញ?

ហឿន៖ បាទ! មកពីនិរតី ពួកខាងតាកែវពួកខាងនិយាយឡូវៗនោះ ។

សុជា៖ ចុះមានឃើញគេសំលាប់មនុស្សនៅនិងដែរទេ?

ហឿន៖ គ្រង់សលាប់បងអត់ដែលឃើញទេ គ្រាន់តែឃើញគេធ្វើទារុណកម្ម គេយកមកកន្ទែងនិងគេសួរចម្លើយមួយកំរិតទៅ ដូចថាវាសួរមិនចេញទើបវាបញ្ជូលទៅព្រៃសរ ទួលស្លែង ។

សុជាៈ ទៅទួលស្វែង?

ហឿនៈ ចា៎! ប៉ុនតែថាវាមានស្លាប់ហើយ ប៉ុនតែស្លាប់និងយើងវាអត់ដឹង ។

សុជាៈ ចុះយ៉ាងម៉េចបានពូដឹងថាគេយកមនុស្សចេញពីកន្លែងនិងទៅដាក់នៅទួលស្វែង ម៉េចបានពូដឹង?

ហឿនៈ អានិងដឹងថាដូចតាមទ័ពដែលនៅការពារនៅហ្នឹង តើពេលគេបញ្ជូននិងគឺម៉ោង៣-៤ ឬក៏ម៉ោង ៦-៧យប់គឺដល់ម៉ោងវាហើយឡានមកហ្នង?

សុជាៈ ហើយឡាននិងដឹងតែមកពី?

ហឿនៈ ឡានអោយតែឡានមកនិងគឺវាដាក់ខ្មែងស្រាប់ហើយ ។

សុជាៈ ខ្មែងយ៉ាងម៉េច?

ហឿនៈ ខែ្មងអាដូចសញ្ញាក្បាលខ្មោច ។

សុជាៈ ទៅគឺដឹងតែចាប់តែម្តង?

ហឿនៈ ទៅដឹងតែចាប់ហើយ ។

សុជាៈ ហើយឡាននិងពូស្គាល់ច្បាស់ថាជាឡានដែលមកពីណាអីណាពូស្គាល់ទេ?

ហឿនៈ ឡាននិងគឺឡានសន្តិសុខខាងនិរតីហ្នឹង វាទទួលខុសត្រូវខាងគុកទួលស្វែង ។

សុជាៈ ពូមានស្គាល់ពីណាគេខ្លះដែលធ្វើការនៅគុកទួលស្វែង?

ហឿនៈ អត់ស្គាល់ហ្នង អត់ស្គាល់ទេ ។

សុជាៈ ចុះហេតុអីបានជាពូដឹងថាជាឡានមកពីខាងហ្នង់?

ហឿនៈ គ្រាន់តែស្គាល់ឡាននិងតែហ្នង ប្រណាំឡានណា៎ ។

សុជាៈ ពីណាគេជាអ្នកប្រាប់ពូ មុនហ្នឹង?

ហឿនៈ មុនហ្នឹង គឺក្មេងវាច្រើនណាស់តែបងអត់ចាំឈ្មោះទេ ។

សុជាៈ លឺតែគេនិយាយ?

ហឿនៈ ចា៎!.. ហើយកាលដែលដាក់ស្តែងដាក់ទារុណកម្មនិងគឺបានឃើញដាក់ស្តែងនិងភ្នែកតែម្តង ដូចថា ចេះកូនក្មេងដែលនៅជាមួយបងអីចេះ ដូចកូនទាហានបងអីចេះវាថាបងនោះឡាននោះមកទៀត ហើយ មកយកមនុស្សទៀតហើយ ។

សុជាៈ អញ្ចឹងបានន័យថាគុកទួលស្វែងហើយនិងគុកដែលនៅមួយជុំវត្តភ្នំហ្នឹង គុកទួលស្វែងធ្ងន់ធ្ងរជាងគុក ដែលនៅវត្តភ្នំ?

ហឿនៈ បាទធ្ងន់ធ្ងរ ព្រោះកន្លែងនិងគឺជាកន្លែងដែលអស់ជីវិតទៅហើយ មានអីទៀត ។

សុជាៈ តើហេតុអីបានជាពូដឹងថាអស់ជីវិត?

ហឿនៈ អស់ជីវិតបើតាមតែបងដឹងគឺថាកាត់ទោសខក្រិដ្ឋហើយ គឺកន្លែងកាត់ទោសស្លាប់សៅនៅនិងហើយ វាអស់កំរិតកសាងហើយ ។

សុជាៈ អានិងគេថាដូចជាលេបគ្រាប់ស្វែងហើយ?

ហឿនៈ បាទ! វាអស់ហើយ វាគ្មានអីសំខាន់ទេគឺមានតែការស្លាប់ ។

សុជាៈ ចុះពូនៅពេលដែលគេចាប់អឿនចាប់អីហើយ ពូត្រូវគេបញ្ជូនទៅព្រៃកន្ទោ ទៅកំពង់ឆ្នាំងនិងតើគេអោយពូធ្វើការលត់ដំអីយ៉ាងម៉េចខ្លះ?

ហឿនៈ ធ្វើនៅព្រៃកន្ទោនិងគឺគេអោយបងបារកំប្លោក ធ្វើស្រែប្រាំងលើកទំនប់ ជីកប្រលាយ ជីកស្រះ

សុជាៈ ហើយការងារម៉ោងពេលអីយ៉ាងម៉េចដែរ?

ហឿនៈ ពេលវេលាម៉ោងល្ងាចយប់ធ្វើតាំងពីម៉ោង៦រហូតដល់ម៉ោង១១យប់ ។

សុជាៈ អានិងធ្វើការនៅព្រៃកន្ទោ?

ហឿនៈ បាទ! ធ្វើការនៅព្រៃកន្ទោ ។

សុជាៈ ចុះបាយទឹកអីយ៉ាងម៉េចដែរ?

ហឿនៈ បាយទឹកហូបម៉ោង១១កន្លះ ម៉ោង១២ចាប់ផ្តើមធ្វើការរហូតដល់ម៉ោង៥ ។

សុជាៈ នៅពេលនិងតើគេនៅតែចាប់មនុស្សទៀតដែលឬទេ ឬក៏យ៉ាងម៉េចទៀត?

ហឿនៈ នៅតែបន្តចាប់រហូត ។

សុជាៈ អានិងចាប់មនុស្សក្រោយនិងចាប់រឿងយ៉ាងម៉េចៗវិញ?

ហឿនៈ នៃបន្តចាប់រហូតនិងគឺវាស្រាវជ្រាវជាប់ដែលថាខ្សែយួននិងណា ។

សុជាៈ មិនមែនដោយសារតែធ្វើការងារអីមិនល្អមិនអីទេណា?

ហឿនៈ គេស្រាវជ្រាវយ៉េង ហើយចោទថាយើងជាខ្សែយួន ដូចថាចាប់ប្អូនឯងមួយទៅជាប់និងនិននិរកាប្អូនឯងនិងទៅ រួចអ្នកឯណោះឆ្លើយថាខ្ញុំបំរើអោយយួនពីឆ្នាំប៉ុនណោះៗទៅ គេស្រាវជ្រាវទៅតាមហ្នឹង រហូតស្រាវជ្រាវចាប់មេអីអស់អីហើយ បំបែកបងបំបែកអីអស់ហើយបានជាគេយកពួកភូមិភាគនិរតីមកក្តាប់ មកគ្រប់គ្រងមក ។

សុជាៈ ចុះដល់ពេលទៅកំពង់ឆ្នាំង?

ហឿនៈ ទៅកំពង់ឆ្នាំងបងទៅកាប់ដី កាប់ភ្នំ បំបែកថ្ម រៀបថ្ម ។

សុជាៈ ហើយពីណាគេជាអ្នកគ្រប់យើងនៅកំពង់ឆ្នាំង?

ហឿនៈ  នៅកំពង់ឆ្នាំងដែលគេយកបងទៅដាក់កន្លែងនិងឈ្មោះញ៉ែរ ភូមិភាគនិរតី ។

សុជាៈ  គាញ៉ែរប្រធានគ្រប់គ្រងធំ?

ហឿនៈ  បាទ! ប្រធានគ្រប់គ្រងធំ ដែលថាទទួលកងពល អនុប្រធានឈ្មោះទុយ ។

សុជាៈ  ចុះពូមានដែលលឺឈ្មោះមេតទេ?

ហឿនៈ  មេតដែលលឺបង ។

សុជាៈ  ឋានៈជាអីដែរ?

ហឿនៈ  ឋានៈជាវរៈសេនាតូចទេ ហ្នឹ! មេតនិងស្គាល់គាត់រាងខ្ពស់ ។

សុជាៈ  សឬខ្មៅ?

ហឿនៈ  គាត់ខ្មៅស្រអែម ។

សុជាៈ  គាត់ថ្នាក់ជាអីដែរ?

ហឿនៈ  ថ្នាក់ប្រហែលជាអនុកងពលហើយ ។

សុជាៈ  ជាមួយនិងញ៉ែរ តើអ្នកណាធំជាង?

ហឿនៈ  ញ៉ែរធំជាង ទុយអនុ មេតនិងប្រហែលជាសមាជិកកងពលនៅភូមិភាគនិរតីទាំងអស់ហ្នឹង ទុយក៏នៅភូមិភាគនិរតី ញ៉ែរក៏នៅភូមិភាគនិរតី ដល់ក្រោយមកដែលបងនៅនិងកំពង់ឆ្នាំងហ្នឹងអស់រយៈកាលជា៣ខែបានគេចាប់ញ៉ែរនិរតីនិងទៀត ។

សុជាៈ  ចុះមេតនោះគេចាប់ទេ ទុយអីហ្នឹង?

ហឿនៈ  ទុយនិងអត់បានចាប់ទេ ព្រោះនៅពេលដែលគេចាប់ញ៉ែរនិងទៅទុយគាត់ឡើងជាប្រធានកងពល ជាប្រធានកងពលនៅរយៈកាលជា២ខែ បានគេដកទុយនិងទៅនៃកាន់ទ័ពទប់ជាមួយនិងយួន ជាមួយនិងវៀតណាម ។

សុជាៈ  ចុះមេតនោះ?

ហឿនៈ  មេតនិងគេដក បានដកនិងមកបានគេបញ្ចូលឈ្មោះសំ រេច ។

សុជាៈ  គាសំ រេច?

ហឿនៈ  បាទ! ទៅកាន់ ។

សុជាៈ  ចុះកាលនិងទៅធ្វើការនៅកំពង់ឆ្នាំងនិងគឺគេនៅបន្តចាប់មនុស្សទៀត?

ហឿនៈ  បាទ! នៅតែចាប់មនុស្សទៀត អ្នកណាទោសត្រូវធ្ងន់អត់បញ្ជូនទៅដាក់កន្លែងសន្តិសុខទេដូចបងថាបើទោសកំរិតដែលថាគេនៅកំពង់តែតាមដានគឺគេបញ្ជូនទៅកន្លែងនិងហើយ ។

សុជាៈ ហើយអ្នកដែលគេបញ្ជូនទៅកំពង់ឆ្នាំងនិងគឺសុទ្ធតែជាអ្នកទោសទាំងអស់?

ហឿនៈ បាទ! អ្នកទោសទាំងអស់ ។

សុជាៈ ហើយមកពីខាងណាដែរ?

ហឿនៈ គ្រប់ភូមិភាគ គ្រប់ខេត្តមិនដឹងជានៅខេត្តណាខេត្តអីទេ ដូចជាខាងបូព៌ាអីចឹងវាជាប់និងនិនទិរការ ដែលថាទោសអីចឹងគឺគេបញ្ជូនមកហើយ ខេត្តសៀមរាបអីចឹងមានទោសគេបញ្ជូនមក មកដាក់កន្លែងមួយជុំនៅកន្លែងកសាងនិងហ្នឹង មិនមែនល្មមណាយកទៅអោយចុចថ្ម ១ថ្ងៃៗមានតែស្លាប់ពី៥នាក់ទៅ១០នាក់ៗ ។

សុជាៈ ស្លាប់ដោយសារអីដែរ?

ហឿនៈ ដោយសារធ្លាក់ពីលើភ្នំមកដែលចុចថ្មរបេះ ដួនកាលវាបែកមកចំក្បាលទៅ ។

សុជាៈ ហើយចំនួនអ្នកដែលធ្វើការនៅនិងមានច្រើនទេ?

ហឿនៈ ទេ! ច្រើនណាស់អូនប្រហែលជាខ្ទង់៣កងពល មើលទៅងងិតរាប់ម៉ឺននាក់ មួយអង្គភាពនេះទៅមួយអង្គភាពនោះទៅ មួយវរៈនេះទៅណែនៗហ្នឹង ប្អូនឯងមានដែលទៅឃើញព្រលានយន្តហោះកំបង់ឆ្នាំងទេ!

សុជាៈ បា!.ដែលទៅ ..ទៅ ។

ហឿនៈ អានិងសុទ្ធតែស្នាដៃហើយអាហ្នឹង ។

សុជាៈ ហើយគេធ្វើបំរុងដាក់អីគេ?

ហឿនៈ ផែនការរបស់វា គឺវាដាក់យន្តហោះពិសេស យន្តហោះប្រដេញណាំ ។

សុជាៈ ហើយធ្វើការអិញ្ចឹងមានជំនាញការនិងវិស្វករអីមកពីខាងណាដែរ?

ហឿនៈ មកពីចិនហ្នឹង ។

សុជាៈ ចិនគេមកធ្វើនៅហ្នឹង?

ហឿនៈ បាទ! បច្ចេកទេសពីចិនហ្នឹង ។

សុជាៈ ចិននៅនិងច្រើនទេ?

ហឿនៈ ច្រើន ដូចជាពីរវរៈសេនាតូច បច្ចេកទេសបុកដី បច្ចេកទេសរុញដីរៀបថ្ម ឆាយដីដែលថាស្មន់ដីច្រើនមុខជំនាញណាស់ គេរៀបចំអគ្គីសនីម៉ាស៊ីនអាឈើទាំងអស់ ខាងខគុនិយមខាងបញ្ជារការ៉ាល់ហោះគ្រប់មុខ ចិនមកមិនមែនពីរវរៈសេនាតូចប្រហែលជាមួយកងពល ដែលមកនៅតំបន់

នៅកំពង់ឆ្នាំងនិងណា ខ្ញុំស្គាល់ច្រើនដែរចិនគាលីជួ តាចូវ អិញ្ចឹងបានន័យថានៅសម័យប៉ុល ពត បងមិនអាចបំភ្លេចបានទេ ។

សុជាៈ ហើយនៅកន្លែងជុំវិញធ្វើការនៅកំពង់ឆ្នាំងនិងមានកន្លែងដែលគេសម្លាប់មនុស្សអីទេ ពូដែលដើរទៅហើយមើលឃើញទេ?

ហឿនៈ ការសំលាប់មានដែរ អ្នកណាដែលធ្វើការមិនល្អត្រឹមកំរិតយុទ្ធជន វាបញ្ជូនមិនដល់ទេវាសំលាប់នៅខាងលិចកំពង់ឆ្នាំងហ្នឹង ខាងលិចព្រលានយន្តហោះហ្នឹង ។

សុជាៈ នៅភូមិអីគេ?

ហឿនៈ នៅត្រង់នោះអត់មានភូមិទេ នៅកន្លែងនោះសុទ្ធតែព្រៃ ។

សុជាៈ ថីបានពូដឹង?

ហឿនៈ ដឹងនៅក្នុងអង្គភាពជាមួយ ដែលជាទ័ពពិសេសវាដែលទៅការពារយើងនិងណា ហើយយើងធ្វើការអីមិនល្អគេចាប់បញ្ជូនយើងមិនដល់ ពិបាកមកដល់ភ្នំពេញវាធ្វើនៅនិងតែម្តងនៅជិតអូរ ។

សុជាៈ ច្រើនគ្នាទេដែលគេសំលាប់នៅហ្នឹង?

ហឿនៈ ច្រើនដែរនិងបើគិតទៅប្រហែលជាមួយអនុសេនាធំ ។

សុជាៈ ប្រមាណទៅ ចូលរយនាក់ហើយមើលទៅ?

ហឿនៈ បាទ! ចូលរយនាក់ហើយ ។

សុជាៈ ពូបានដឹងដំណឹងនិងតាមរយៈពីណាគេ តើពូទៅឃើញផ្ទាល់ឬក៏ដឹងតាមតែគេនិយាយ?

ហឿនៈ ឃើញផ្ទាល់និងភ្នែកហ្នឹង មួយឈ្មោះនៃសុនៗគ្នាមកពីរែកដីមិនទាន់និងបានស៊ីបាយផង កំពង់តែតំរង់ជួរចាប់ព្រើបប្រដោយ ។

សុជាៈ ចុះឃើញតែគេចាប់ ហើយត្រង់សំលាប់?

ហឿនៈ តែចាប់បញ្ជូនចងស្លាបសេក....

សុជាៈ យកទៅហ្នឹង?

ហឿនៈ បាទ! យកទៅហ្នឹង ។

សុជាៈ ចុះពេលដែលគេកំពង់តែសំលាប់និង តើពូមានបានឃើញទេ?

ហឿនៈ ទេ! ទេ!អត់បានឃើញទេ ។

សុជាៈ ឈ្មោះសុនហ្នុ៎?

ហឿនៈ បាទ! ។

សុជាៈ ចុះមានដែលទៅមួយដុំមាត់អូរនិងមានដែលឃើញរណ្តៅសាកសពអី តើមានឃើញទេ?

ហឿនៈ ថីក៏មិនឃើញ ។

សុជាៈ តែត្រង់ឃើញគេសំលាប់ផ្ទាល់អត់ដែលឃើញទេ?

ហឿនៈ អត់ឃើញទេ តែគ្រាន់តែថាវាអោយយើងទៅធ្វើការទៅកាប់ឈើអីហ្នឹង មានអ្នកណាខ្លាចហើយអាអ្នកដែលសំលាប់និងវាមានអ្នកល្អនិងអ្នកអាក្រក់ដែរ ហ៎យវាថាថ្ងៃមុនគេយកពួកនោះមកសំលាប់នៅហ្នឹង ។

សុជាៈ ឈ្មោះអីគេដែលប្រាប់ពូ?

ហឿនៈ ឈ្មោះរី ដែលនៅភូមិអន្លង់ថ្មយើងនេះ ។

សុជាៈ អន្លង់ថ្មស្រុកណាដែរ?

ហឿនៈ ស្រុកបារាយណ៍យើងនេះ ។

សុជាៈ ជាទាហាន?

ហឿនៈ បាទ! ។

សុជាៈ តួនាទីគាត់ធ្វើអីគេ?

ហឿនៈ គាត់តួនាទីជាយុទ្ធជនទេ ប៉ុនត្រង់ថាគេទៅយាមនៅហ្នឹង អានិងបងអស់សិទ្ធអស់អំណាចហើយ គឺនៅជាអ្នកទោសហើយអាហ្នឹង ។

សុជាៈ ឈ្មោះរីបានប្រាប់ពូប៉ុន្មានដង?

ហឿនៈ ប្រាប់តែមួយដងទេ ។

សុជាៈ ហើយរីនិងជាអ្នកចូលរួមសំលាប់និងគេដែរ?

ហឿនៈ បាទ! គ្រាន់តែថាការពារហើយកូនទាហានគេធ្វើ ។

សុជាៈ ចុះនៅធ្វើការនៅកំពង់ឆ្នាំងនិងមានឃើញអ្នកធំអ្នកអីគេទៅមើលទេ ដូចថ្នាក់អៀង សារី ហើងនិងថ្នាក់តាខៀវអីមានដែលទៅមើលទេ?

ហឿនៈ ដែលទៅដែរ ។

សុជាៈ ដែលទៅដែរ ពូឃើញហ្នឹង?

ហឿនៈ ឃើញជិះកាប៉ាល់ហោះចុះនៅនិងព្រលាននិងហ្នឹង ។

សុជាៈ ពីណាគេទៅ?

ហឿនៈ ឃើញខៀវ សំផន ហើយនិងតាប៉ុល ពត នេះ ។

សុជាៈ ហើយគាត់មានដែលនិយាយឬក៏ធ្វើមេទិញអីនៅហ្នឹងទេ?

ហឿនៈ អត់ទេ ហើយយើងគ្រាន់តែឃើញពីចំងាយទេ ។

សុជាៈ ចុះតាខៀវដែលបង្រៀននយោបាយនោះមានដែលទៅទេ?

ហឿនៈ ទៅ ។

សុជាៈ ចុះអៀងសារី?

ហឿនៈ ទៅ អៀង សារី មុខរាងច្រេះៗស្តើងដូចតាកុងចឹង ប៉ុនគ្រាន់តែខ្មៅ ។

សុជាៈ ពូទៅដល់កំពង់ឆ្នាំងនិងគេមានដែលបង្រៀននយោបាយ ឬចូលមេទិញគេអីយ៉ាងម៉េចទេ?

ហឿនៈ គេបង្រៀននយោបាយយើងត្រង់ថា អោយយើងខំកសាងខ្លួនព្រោះយើងជាប់និងនិននិរការនិងខ្សែរក្បត់ បើអ្នកណាដែលថាមិនកសាងមិនប្រឹងកសាងខ្លួនទេអានិងគេ ។

សុជាៈ គេសម្លាប់ហើយ?

ហឿនៈ គេសម្លាប់ហើយ ។

សុជាៈ ចុះដល់ពេលដែលទៅវៃយួនចូលទៅក្នុងកងពលអី វរៈអីដែរ?

ហឿនៈ កងពល៣៥០ ។

សុជាៈ ពីណាគេជាប្រធានកងពល?

ហឿនៈ ប្រធានកងពលឈ្មោះកែវ ។

សុជាៈ ចុះទៅដល់មានបានវៃចូលទៅវៀតណាមទេ?

ហឿនៈ គ្រាន់តែទៅដល់ចូលបាន៣ថ្ងៃនិងដាច់ភ្នំពេញ ។

សុជាៈ ចូលទៅជីតាយនីញនិងហ្ន៎?

ហឿនៈ បា៎! ។

សុជាៈ ចុះដល់ពេលដែលចូលទៅវៃនិងមានបានដុតផ្ទះប្រជាជនវៀតណាមទេ?

ហឿនៈ ចូលទៅវៃបានមួយថ្ងៃមួយយប់ដែរ ។

សុជាៈ ចុះមានដែលចាប់បានទាហានវៀតណាមវៀតអីទេ?

ហឿនៈ អត់ទេ អត់ដែលមានទេ ។

សុជាៈ ចុះប្រជាជនវៀតណាម?

ហឿនៈ ចាប់បាន ។

សុជាៈ ចុះគេយកទៅធ្វើម៉េចទៅ?

ហឿនៈ ចាប់បានក៏ខាងទ័ពនិងអត់ដឹងទេ ព្រោះចាប់បានបញ្ជូនមកក្រោយមក គេថាកុំអោយសំលាប់គឺគេចង់យកមកសម្ភាស តែរឿងមកក្រោយបងអត់ដឹងទេ គេសួរចំលើងចេះៗគេអោយនិយាយពីអីចេះមួយចុះមួយ ។

សុជាៈ ចុះសម្ភាសនិងតើពីណាគេជាអ្នកសម្ភាស?

ហឿនៈ អ្នកសម្ភាសនិងគេយកពីខាងគេដែលនៅក្រោយហ្នឹង គេសម្ភាសដូចជាប្អូនឯងអញ្ចឹងមិនដឹងជាឈ្មោះអ្នកណា បងអត់ដឹងដែរប៉ុន្តែបងលឺនៅក្នុងវ៉ាដ្យូចឹងទៅណា៎ ថាអោយឆ្លើយចេះៗមួយទៅ

សុជាៈ ចាប់បានញឹកញាប់ទេ?

ហឿនៈ អោយតែវៃចាប់បានហើយ ។

សុជាៈ ចាប់បានប៉ុន្មាននាក់ទៅនៅដែលពូទៅប៉ុន្មានថ្ងៃហ្នឹង?

ហឿនៈ ខ្ញុំទៅចាប់បានតែ៣នាក់ទេ ។

សុជាៈ សុទ្ធតែជាជនស៊ីវិលទាំងអស់?

ហឿនៈ ប្រជាជនដូចយើងនៅតាមស្រុកតាមភូមិអញ្ចឹង រួចចេះតែថាចាប់បានទៅថាចាប់បានទាហានយួនថាខ្មាំងយួនចេះទៅ តែតាមពិតចាប់បានជាប្រជាជនដែលគ្នាជាអ្នករកស៊ីធ្វើស្រែធ្វើចំការមានផ្ទះតូចតាចដូចយើងអញ្ចឹងទៅណា៎ រួចយកមកសុទ្ធតែអោយសម្ភាសថាសុទ្ធតែធ្វើជាទាហានយួន ។

សុជាៈ អញ្ចឹងបង្ខំអោយអ្នកនិងថាធ្វើជាទាហានយួន?

ហឿនៈ អោយឆ្លើយថាធ្វើជាទាហាន ។

សុជាៈ ចុះនៅពេលដែលចាប់បាននិងគេមានអាវុធអីនៅជាប់និងដៃទេ?

ហឿនៈ គ្មានទេ ប្រជាជនយើងសុទ្ធសាត ជួនកាលគ្នាមកបេះបន្លែត្រកួនអីទៅពទ័ចាប់គ្នា... អូរចាប់បានយួនប៉ុណ្ណេះក្បាល វៃបានខ្មាំងយួនប៉ុណ្ណេះក្បាលតែតាមពិតមិនមែនទេគឺប្រជាជនទេ ។

សុជាៈ ចុះពេលចូលទៅដល់ភូមិវៀតណាមចូលដល់ផ្ទះវៀតណាមអី មានដុតផ្ទះដុតអីទេ?

ហឿនៈ អោយតែវៃគឺឆេះហើយអាអូន ។

សុជាៈ ចុះនៅពេលដែលយើងវៃហើយចូលទៅដល់ អត់មានដុតអីផ្សេងទេហើយអាវៃបាញ់ទៅគឺវាឆេះហើយតែអាក្រៅពីវៃបាញ់ឆេះនិងមានដុតទេ?

ហឿនៈ ដុត...គ្មានទុកទេផ្ទះហ្អែង ផ្ទះវៀតណាមជាប់គ្នារហូតដុតតែមួយឆេះទាំងអស់ មានពីរបីជួរផ្ទះនៅវៀតណាមប្អូនឯងមិនដឹង ។

សុជាៈ តែនៅពេលដែលចូលទៅប្រជាជនចេញអស់ពីភូមិនិងហើយឬក៏នៅក្នុងភូមិនិងដែរ?

ហឿនៈ ដល់យើងចូលទៅនិងទាហានវៀតណាមវាមិននៅនិងប្រជាជន ដល់យើងវៃទៅវៀតណាមដកទៅ វាជំលៀសប្រជាជនវាអត់ទាន់ វានៅសេសសល់អាត្មាដែលជាអ្នកក្រីក្រដែលគ្មានអីអូសដែលគេហៅថាដឹកជញ្ជូននិងគេ ហើយក៏ចាប់បានទៅជួនកាលក៏វៃកាត់ផ្លូវគេចាប់បានទៅអញ្ចឹង ។

សុជាៈ អញ្ចឹងកាលពូទៅនិងមានឋានៈជាអីគេដែរ?

ហឿនៈ ត្រឹមតែជាយុទ្ធជនទេ ព្រោះគេដកអស់ហើយបើមនុស្សទៅពីទោស ។

សុជាៈ គេបញ្ជូនពីកំពង់ឆ្នាំងទៅ?

ហឿនៈ បាទ! គេបញ្ជូនពីកំពង់ឆ្នាំងទៅ ។

សុជាៈ ទៅប្រហែលជាប៉ុន្មាននាក់?

ហឿនៈ ទៅច្រើនដែរមួយវរៈសេនាតូច ប្រហែលជា៣០០នាក់ ។

សុជាៈ បាន៣ថ្ងៃដាច់ពេញ?

ហឿនៈ ៣ថ្ងៃដាច់ពេញ ។

សុជាៈ រត់មក!

ហឿនៈ រត់មកជិះរថក្រោះឆ្លងទន្លេបិទ ។

សុជាៈ ពូបានឆ្លងកាត់របបខ្មែរក្រហមអញ្ចឹង តើពូយល់របបនិងយ៉ាងម៉េចដែរ?

ហឿនៈ ពូបានឆ្លងកាត់ជាមួយខ្មែរក្រហមអស់រយៈកាល៣ឆ្នាំ៨ខែបងយល់ច្បាស់ ប៉ុន្តែនៅកងសង្គមថារើបំរាស់វាមិនរួចណា៎ បងយល់ច្បាស់ថារបបនេះរបបប្រេដការដែលហៅថារបបកុម្មុយនីស ចឹងគឺបងមានខត្តមគតិមួយដែលស្នេហាជាតិ អោយតែមានរបបណាដែលក្រៅពីនេះគឺបងប្រែក្រឡះហើយអញ្ចឹងបានជាបងចងចាំនៅក្នុងប្រវត្តិសាស្ត្ររបស់បង ដ្ដាំកូនដ្ដាំចៅរហូតទាល់តែសព្វថ្ងៃថារឿងនៅក្នុងសម័យប៉ុល ពត របប ប៉ុល ពត អោយតែមានម៉ោងណាដែលកើតរបបនិងគឺកូនឯងក្រោកតស៊ូទៅវៃប្រឆាំងនិងរបបនិងកុំអោយវិលត្រឡប់បាន គឺវាលំបាកណាស់លំបាកតាំងពីការរស់នៅ តាំងពីសេរីភាព ការហូបចុកសិទ្ធសេរីដើរហើរនិយាយស្តីគឺយើងគ្មានសិទ្ធទេ អានេះរបៀបថាយើងមើលឃើញហើយប៉ុន្តែយើងជាប់គុកដែលអត់ជាង ចឹងបងមិនអាចហៅថាមិនឲ្យអារបបនិងវិលបានទេ ទោះបីជាបងចាស់ល្វិតល្វន់ប្អូកក៏កំរិតនេះក៏ដោយ តែមានសម័យប៉ុល ពតមានផ្ទុះឡើងជាលើកទី១ទី២គឺបងធ្វើទាហានទៀតហើយ ។

សុជាៈ ចុះកាលនិងតើពូមានឃើញថាការដឹកនាំដែលនៅជំនាន់និងមានការល្អត្រឹមត្រូវដែរទេ?

ហឿនៈ ដែលសម័យនោះអ្នកស្នេហាជាតិយើងណាមួយគឺអតមានទេ សុទ្ធតែនៅលាក់ខ្លួនបង្កប់ខ្លួនទោះបីជាប្អូនឯងមានឧត្តមគតិមួយស្នេហាជាតិឬគោលនយោបាយណាមួយសំខាន់ៗ គឺប្អូនឯងមិនហ៊ានប្រាប់ខ្ញុំទេខ្លាចខ្ញុំដឹងពីប្អូនឯងរាយការណ៍អោយអ្នកនោះវិញ អញ្ចឹងដែលថាការដឹងយល់ច្បាស់ពីគ្នាហើយក៏មិនហ៊ានប្រាប់គ្នាដែរថាយើងអញ្ចេះៗមួយ ។

សុជាៈ កាលពីជំនាន់ប៉ុល ពត ពូមានដែលសុំគេមកលេងផ្ទះទេ?

ហឿនៈ ខ្ញុំសុំគេមកមួយដង ។

សុជាៈ បានមកផ្ទះដែរ?

ហឿនៈ បាទ! ។

សុជាៈ បានមកប៉ុន្មានថ្ងៃ?

ហឿនៈ មកតែ៣ថ្ងៃទេ ហើយម្យ៉ាងយើងនៅទ័ពនិងគឺវាមិនចង់យើងមកលេងផ្ទះទេ ព្រោះវាមិនចង់ឲ្យពួកយើងដឹងពីការធ្វើទុក្ខលំបាកមកលើឪពុកម្តាយយើង អត់ស្បៀងបង្អត់អាហារហូបមិនគ្រប់គ្រាន់ វាធ្វើបាបមិនអោយឈប់សំរាក ធ្វើការមិនដែលមានពេលវេលា អញ្ចឹងយើងនៅទ័ពមកឃើញឪពុកម្តាយយើងលំបាកនៅខាងក្រោយវាការឈឺចាប់និងតស៊ូ វាបិទសិទ្ធសេរីភាពគេមិនអោយ ។

សុជាៈ តែមកបាន៣ថ្ងៃពូឃើញអ្នកដែលនៅនិងភូមិស្រុកនិងយ៉ាងម៉េចដែរ?

ហឿនៈ ខ្ញុំដែលមកគឺឃើញជីវភាពប្រជាជនដែលនៅខាងក្រោយនិងគឺវាលំបាក លំបាកតាំងពីការរស់នៅតាំងពីការហូបចុកទាំងអស់ ។

សុជាៈ ចុះពូមានអារម្មណ៍ម៉េចដែរចំពោះរបបបែបហ្នឹង?

ហឿនៈ ដែលក្នុងគោលជំហរនយោបាយគំនិតរបស់បងគឺវាមានការលំបាក របបនេះគឺថាអ្នកណាមួយដែលមានគំនិតស្នេហាជាតិ គឺបងប្រែក្រឡះហើយមិនរួសនៅក្នុងសង្គមនេះទេ អញ្ចឹងរហូតមកពីនិងទៀតអានេះបងនិយាយសារនេះវិញហើយណា បងអឿនប្រធានរបស់ខ្ញុំនិងបានជាគាត់មានឧត្តមគតិមួយដែលហៅថាកសាងកំលាំងផ្ទៃក្នុងដែលគេហៅថាខ្មែរស អោយមានចលនាតស៊ូមួយទៀតអញ្ចឹងគាត់បង្កប់ក្នុងមួយកងពលនិងបានហើយ អានិងបងនិយាយត្រឡប់មកវិញ គាត់ដកបងមកបង្កប់ខ្លួននៅកំពង់ចាមនេះ អោយខ្ញុំមួយកងតូចនិងឡានអាសេកង់សេ៦ ដឹកកាំភ្លើងមកលាក់បង្កប់នៅកំពង់ចាម ដែលបង្កប់និងទៅគេចាប់មេៗនិងអឿនអស់ទៅ ចាប់ធុចអស់ទៅវាបែកការ ដែលបែកការនិងហើយដែលបងជាប់និងនិននិរការនយោបាយនិងណា ។

សុជាៈ ចុះគេរកឃើញពូដែលជាខ្សែរយេះរបស់អឿនដែរទេ នៅពេលដែលគេចាប់អឿនហើយ?

ហឿនៈ ដែលគេចាប់បងជាប់និងនិននិរកាបងប្រែវត្តិរូប ។

សុជាៈ ប្រែប្រវត្តិរូបម៉េច?

ហឿនៈ ពីដើមថានៅសង្កាត់ក្រវ៉ា ភូមិបាក់ស្នា ស្រុកបារាយណ៍ចេះទៅណា ដល់ពេលនេះយើងប្រែជាទៅដាក់នៅឯសៀមរាបឯណាដែលយើងធ្លាប់ស្គាល់ទៅណា អិញ្ចឹងបានរស់បើនៅតែអិញ្ចឹងគឺអត់រស់ទេ អត់រស់ទេអូនឯសួរទៅសួរដូចចាញ៉ារដែលនៅបាក់ស្នាដែលអនឯងសម្លាសនោះ ញ៉ារក៏ជាប់និងនិននិរកាដូចគ្នាដែរ ជិតស្លាប់រស់ដូចគ្នានិងឯង នៅទួកគោកនៅនិងបែកត្រឡោកនិងឯងនៅម៉ាជាមួយគ្នានិងឯង ។

សុជាៈ ចុះពូថាអឿនបង្កប់នៅកំពង់ចាមនេះ តើពូដឹកអាវុធមកមែន?

ហឿនៈ បាទ! ដឹកមកមែន ។

សុជាៈ ដែលបំរុងផ្ទុះនិងគេអោយធ្វើម៉េច?

ហឿនៈ ដល់ពេលដឹកនិងហ៎យដល់ម៉ោង ដល់ម៉ោងហើយគេអោយដឹកអាវុធទៅដាក់នៅពោធិនគុងនៅកន្លែងប៉េះខៀវ វៃយកពោធិនគុងវៃយកព្រលានយន្តហោះ វៃយកកន្លែងឃ្លាំងកាំភ្លើងធំរកន្លែងរថក្រោះវៃយកនិងហើយ ហើយមួយវរៈសេនាធំទៀតវៃយកប៉ុសរាជ្យហ្វូង ដល់ទៅហើយបែកការទៅហើយដែបការ បែកការចុះបែការឡើងចាប់មេពីបមេស្រែកថាអ្នកនេះអ្នកនោះមួយ កុំអីផ្ទុះអាវុធតាំងពីឆ្នាំ៧៦នោះ ។

សុជាៈ ៧០ប៉ុន្មាន?

ហឿនៈ ៧៦នោះ ប៉ុនវាធ្វើការអត់ចេញ ខ្ញុំវៃនៅនោះហើយខាងកំពង់ចាម នេះជារឿងពិតព្រោះជាការតស៊ូរបស់បង បងនិយាយពិតមិនមែនជាក្មេងខ្លាយទេ ។

សុជាៈ បើសិនជាគេរកឃើញពូដែលស្និតជាមួយនិងអឿននិងប្រហែលជា?

ហឿនៈ ស្លាប់ហើយ ប្អូនឯងប្រហែលជាមិនបានជួបមុខបងទេ ។

សុជាៈ ពូលាក់ប្រវត្តិរូប?

ហឿនៈ បាទ! លាក់ប្រវត្តិរូបសុទ្ធតែលាក់ប្រវត្តិរូបទាំងអស់ អាខ្លះដាក់ខាងនៅសង្កាត់ក្រវ៉ាចឹងវាទៅដាក់នៅសង្កាត់អ៊ីកំពង់ចាមទៅ ដល់វាយកប្រវត្តិរូបអាមេវាថ្មីមកយកប្រវត្តិរូបយើងទៅស្រាវជ្រាវវាអត់នៅនេះទេ ដល់ប្អូនស្រាវជ្រាវទៅថាវាមិនមែននៅភូមិបាក់ស្នាទេ ដល់អិញ្ចឹងទៅវាមើលទៅឈ្មោះអានេះវាមិននៅនេះទេវានៅនោះតើ មានជាប់និងនិននិរកានិងអ្នកនេះណា បើបានរស់បើ

មិនថាជាអញ្ចឹងទេមិនបាច់ទេចប់បណ្តោយ អាប្រវត្តិរូបដែលនៅមេយើងចាស់និងដល់ពេលនោះ វាខ្វាត់ខ្វាយអស់ទៅ អញ្ចឹងវាក្តាប់អត់បានបើថានៅដដែលមិនបាច់ទេ ។

សុជាៈ ពូដែលមកសួរនាំដូចខ្ញុំមកសួរនាំពូអញ្ចឹងទេ?

ហឿនៈ សួរ! មកសួរជូនកាលខ្ញុំនៅឯណោះទេតែគេមកសួរនាំម៉ែឪខ្ញុំនៅឯផ្ទះនេះ គេមកលបសួរប្រវត្តិរូប ប្រវត្តិរូបនែសផ្ទេប អូរមិនមែនប្រវត្តិរូបសផ្ទេបទេគេហៅប្រវត្តិរូបពិស្តារ ។

សុជាៈ គេមកសួរឪពុកម្តាយយើង?

ហឿនៈ បាទ! គេមកសួរឪពុកម្តាយយើងដើម្បីយកទៅតាមដានយើង ថាតើប្រវត្តិរូបយើងនិងវាល្អឬក៏មិនល្អ បើមិនល្អគឺនៅនិងហើយ ។

សុជាៈ ចឹបានដាពូដឹង?

ហឿនៈ ខ្ញុំមកលេងផ្ទះឪពុកម្តាយប្រាប់ ថាមានអ្នកនេះៗគេមកសួរ ។

សុជាៈ ចុះនៅនោះ នៅភ្នំពេញគេមានដែលសួរនាំពូផ្ទាល់ទេ?

ហឿនៈ សួរ សួរគ្រប់តែគ្នាហ្នឹង ។

សុជាៈ ហើយពូក្រោយពូ៧៩មកមានដែលគេមកសួរនាំពូអញ្ចឹងទេ?

ហឿនៈ អត់ទេអូន មិនដែលទេបាត់ឈឹងហើយបងក៏ខ្វះជីវភាពទៅក្រីក្រទៅក៏ចេះតែរស់នៅតាមភូមិជនបទនៅតាមបងប្អូនប្រជាជនទៅ ។

សុជាៈ ចុះពូនៅពេលដែលមានខ្ញុំមកសួរនាំពូពីរឿងរ៉ាវខ្មែរក្រហមចឹង តើពូមានអារម្មណ៍យ៉ាងម៉េចដែរ?

ហឿនៈ ខ្ញុំមានអារម្មណ៍រីករាយជាមួយប្អូន ហើយសូមថ្លែងអំណរអរគុណដែលបានមកសួរនាំពីប្រវត្តរបស់ពូណាំ ថាការដូរចត់របស់បងនៅក្នុងប៉ុល ពត ដែលធ្វើការដាក់ទារុណកម្ម ហើយវាត្រឡប់មកកាន់ជ័យជំនះហើយវាប្រែត្រឡប់ថាយើងជាខ្មាំងវិញ អញ្ចឹងដែលបងលើកឡើងថាអោយចងចាំនៅក្នុងប្រវត្តិសាស្ត្រ ក្នុងខួរក្បាលខ្ញុំនៅក្នុងខត្តមគតិរបស់ខ្ញុំ រឿងប៉ុល ពត ដែលខ្ញុំលើកឡើងថាមិនអាចផ្សះផ្សារគ្នាបាន ចំពោះបងគឺវាជូរចត់ណាស់ គួរណាស់ដែលបងតស៊ូមុតដៃមុតជើងមានរបួសពិការគួរណាស់តែអោយមានសិទ្ធសេរីភាព ហើយគេចាត់ទុកយើងជាខ្មាំង បានជាបងថាវាមិនអាចបំភ្លេចបានទេដែលថាមួយឆាកចជីវិតរបស់រហូតដល់ស្លាប់ ហើយស្លាប់ក៏ពូចងចាំទៅកូនក្រោយថាសម័យប៉ុល ពត គឺកូនកុំសារភាពហ្នង ។

សុជាៈ ចុះពូគួរថាត្រូវតែបំភ្លេចចោលទេរឿងហ្នឹង?

ហឿនៈ បាទ ។

សុជាៈ អារឿងរ៉ាវប៉ុល ពត និងគួរតែបំភ្លេចចោលឬក៏បន្តអោយក្មេងៗដឹងទៅទៀត?

ហឿនៈ ខ្ញុំអត់បំភ្លេចចោលទេគឺខ្ញុំដឹកនាំក្មេងៗប្រាប់ជីវប្រវត្តដែលវាកាន់អំណាចឃោរឃៅនោះណា៎ ចឹងបានជាខ្ញុំលើកឡើងថាកូនក្មួយៗទាំងអស់ ថាពូដែលនៅរស់នៅក្នុងសម័យប៉ុល ពត នៅសង្គមប៉ុល ពត ប្អូនឯងគ្មានសិទ្ធសេរីភាពអិញ្ចេះទេ កូនឯងគ្មានសិទ្ធសេរីភាពចេះទេ គ្មានយើងចង់ហូបស្មើណាបានស្មើនិងទេ យើងចង់ជិះម៉ូតូស្មើណាជិះបានទេ ចង់ជិះឡានពេលស្មើណាជិះពេលនិងបានទេ ដើរទៅម៉ោងណាក៏បានទេ គឺដើរត្រូវតែមានសុំច្បាប់ទំលាប់ សូមបីទៅបត់ជើងក៏ប្រាប់ដែរថាបងខ្ញុំសុំទៅបត់ជើងបន្តិចអានេះវាអស់ហើយណាអូន របបវានេះវាឃោរឃៅផ្តាច់ការនិងវាហួសនិស្ស័យទៅហើយ អិញ្ចឹងបានខ្ញុំប្រាប់កូនចៅកូនក្មួយថា រឿងសម័យប៉ុល ពត ឬក៏របបប៉ុល ពត ក្មួយកូនទាំងអស់សូមកុំភ្លេចចងចាំនៅក្នុងប្រវត្តិសាស្រ្ត សរសេរជាក្រាំងមួយសំរាប់តទៅកូនតទៅចៅទៀត ។

សុជាៈ ចុះការដែលខ្ញុំមកសួរនាំនេះ តើវាមានប្រយោជន៍អីដល់ប្រជាជនខ្មែរឬដល់ពូដែរ?

ហឿនៈ ក្មួយមកនេះគឺប្រយោជន៍ដែលមានសារៈសំខាន់និងការរីកចំរើន ម្យ៉ាងទៀតគឺជាប់និស្ស័យក្នុងការនយោបាយដែលមកចង់ដឹងពីជីវប្រវត្តិរបស់បងពីសម័យប៉ុល ពត អិញ្ចឹងប្អូននេះទៅក៏ប្អូនបានជួយផ្សព្វផ្សាយក្នុងសម្ភាសរបស់បងនិងថាតើនៅរបបប៉ុល ពត និងវាចេះៗមួយគឺវាបានរីចំរើននៅក្នុងនយោបាយមួយដែរ ។

សុជាៈ ចុះក្រោយមកនេះតើពូមានដែលលឺរឿងរ៉ាវដែលគេបំរុងបង្កើតតុលាការដើម្បីកាត់ទោស មេដឹកនាំខ្មែរក្រហមអី តើពូមានដែលលឺទេ?

ហឿនៈ ដែលលឺ ។

សុជាៈ លឺតាមរយៈអីគេ?

ហឿនៈ តុលាការនេះគឺបងមានឧត្តមគតិមួយថាអរ អរត្រង់ថាអោយប្រជាជនខ្មែរដឹងថាទោសខ្មែរក្រហមដែលវាធ្វើបាបប្រជាជនអស់រយៈកាល៣ឆ្នាំ៨ខែមកថាតើពួកវាមានទោសកំរិតណា ។

សុជាៈ ហើយពូដឹងដំណឹងនិងតាមរយៈណា?

ហឿនៈ តាមវិទ្យុ ។

សុជាៈ តាមវិទ្យុប៉ុស្ដយើងហ្នឹង?

ហឿនៈ ប៉ុស្ដយើងហ្នឹងអា១០៣ ប៉ុស្ដF.Mយើងហ្នឹង ។

សុជាៈ ហើយពេលលឺនិងតើពូដឹងថាគេកាត់ទោសត្រឹមមេដឹកនាំត្រឹមថ្នាក់ណាដែរ?

ហឿនៈ   កាតទោសខ្មែរក្រហម  កាត់ទោសត្រឹមថ្នាក់រដ្ឋមន្ត្រី ។

សុជាៈ   ចុះថ្នាក់ក្រោមនេះគេអត់យកទៅកាត់ទោសទេនែ?

ហឿនៈ   អត់យកទេ ។

សុជាៈ   ចុះបើតាមគំនិតពូ  ពូគិតថាគួរតែយកមេដឹកនាំត្រឹមថ្នាក់ក្រោមៗទៅកាត់ទោសដែរអត់ទេ?

ហឿនៈ   បើតាមគមនិតខ្ញុំត្រូវតែប្រមូល   ព្រោះមេភូមិមេឃុំមេសង្កាត់នៅក្រោមនិងក៏វាធ្វើបាបប្រជាជន ដែរ  ព្រោះការបំពាក់បំប៉នពីពួកនិងមកដែរ  បង្អត់បាយប្រជាជនសម្លាប់ប្រជាជនជាពិសេសអ្នក ដែលសម្លាប់ខ្លាំងគឺនៅតាមត្រឹមភូមិថ្នាក់ឃុំហ្នឹង   សម្លាប់ប្រជាជននៅក្នុងសហករណ៍និងធ្វើបាបគ្នា មិនអោយស៊ីឆ្អែត  សូម្បីតែគ្នាមានកូនមួយខែក៏អោយធ្វើការដែរ ។

សុជាៈ   ហើយពូគិតថាគួរតែដាក់ទោសត្រឹមកំរិតណាអោយសំនិងកំហុសទោសរបស់ពួកគេ?

ហឿនៈ   ខ្ញុំបើនិយាយពីដាក់ទោស  បើនិយាយពីកំរិតវាត្រឹមថ្នាក់ឃុំថ្នាក់ស្រុកកំរិតត្រូវតែដាក់គុកមួយជីវិត បណ្តោយ  អានិងបានតបស្នងសងគុណជាមួយប្រជាជនដែលវាធ្វើបាបអានិងបានវារួចគ្នា ។

សុជាៈ   ចុះពូយល់ថាការកាត់ទោសនិងវាបានផ្តល់ប្រយោជន៍អី   ដល់ពូឬក៏ដល់ប្រជាជននិងប្រទេសជាតិ យើងដែរ?

ហឿនៈ   កាត់ទោសនិងវាបើតាមខ្ញុំពិនិត្យម្យ៉ាងវាក៏បានប្រយោជន៍ដល់ប្រទេសជាតិយើងដែរ   ម្យ៉ាងក៏ឲ្យ បានអស់ចិត្តពីប្រជាពលរដ្ឋ ។

សុជាៈ   អោយប្រជាពលរដ្ឋអស់ចិត្តយ៉ាងម៉េច?

ហឿនៈ   អស់ចិត្តត្រង់ថានៅពេលដែលវាធ្វើបាបកម្មជាមួយប្រជាជនកាលសម័យនោះណា  ចឹងកាត់ទោស ទៅដឹងថាទោសខ្មែរក្រហមអស់រយះកាល៣ឆ្នាំ៨ខែនិងវាទោសកំរិតនេះ   ហើយថ្នាក់ដឹកនាំនេះវា ត្រូវកំរិតនេះ ។

សុជាៈ   ហើយពូគិតថាតុលាការដែលបំរុងបង្កើតឡើងនៅខាងមុខនេះ  និងអាចរកយុត្តិធម៌ជូនប្រជាជនខ្មែរ យើងបានទេ?

ហឿនៈ   គឺរកយុត្តិធម៌ត្រឹមត្រូវហើយ ។

សុជាៈ   រកយុត្តិធម៌ជូនពូ?

ហឿនៈ   បានជូនខ្ញុំ ។

សុជាៈ   ចុះពូយល់ថាយ៉ាងម៉េចបានជាតុលាការអាចរកយុត្តិធម៌ជូនពូបាន?

ហឿនៈ   អានេះតាមយល់គំនិតរបស់ខ្ញុំគឺមានថា  អង្គការមួយស្វែងរកយុត្តិធម៌មួយអោយប្រជាពលរដ្ឋខ្មែរណា  ហើយអានេះវាជាការត្រឹមត្រូវច្បាស់លាស់ ។

សុជាៈ   ចុះពូដែលលឺនិងតើពូដឹងថាតុលាការនិងមានការចូលរួមពីខាងណាខ្លះ?

ហឿនៈ   ក្តាប់មិនបានដែរ ដូចថាវាច្រើនពេក ។

សុជាៈ   ដូចថាតុលាការនិងវាមានតែខ្មែរយើងឬក៏មានការចូលរួមពីបរទេសដែរ?

ហឿនៈ   មានបរទេសដែរ ខបួមតាំងពីលុយកាកក់ជួយធ្វើច្បាប់កាត់ទោសខ្មែរក្រហម ។

សុជាៈ   ហើយពូគិតថាការចូលរួមនិងវាអាចផ្តល់យុត្តិធម៌ធំសំរាប់ប្រជាជនខ្មែរ  សំរាប់ប្រទេសជាតិ?

ហឿនៈ   បា៎!  វាម៉្យាងវាផ្តល់យុត្តិធម៌ដល់ប្រជាជនខ្មែរ  ម៉្យាងដល់នៃវែកមុខវែកមាត់អោយដឹងពីកំរិតការដាក់ទោសរបស់ប៉ុល  ពត ។

សុជាៈ   ហើយតុលាការនិងគួរតែមានការចូលរួមពីសហគមន៍អ៊ឺរុបចូលរួមដែរឬក៏មិនចាំបាច់ទេ?

ហឿនៈ   អានេះបើតាមមតិរបស់ខ្ញុំ     បើនិយាយអោយចំសមាគមន៍អន្តរជាតិគេមកជួយក៏បានខ្មែរខ្លួនឯងធ្វើផ្ទាល់ក៏បានដែរ  អោយតែកាត់ទោសខ្មែរក្រហម ។

សុជាៈ   អញ្ចឹងយុត្តិធម៌មានន័យថាម៉េចដែរ?

ហឿនៈ   ត្រឹមត្រូវហ្នឹង ។

សុជាៈ   តើពូចង់បានពាក្យនិងទេ?

ហឿនៈ   ចង់បាន   ខ្ញុំទៀមទាដែរដល់ពេលអញ្ចឹងយើងទុកបន្ទាយអញ្ចឹងទៅ   ខ្មែរក្រហមកាប់សំលាប់ប្រជាជនខ្មែរយើងអស់ជាង៣លានជាង  គឺថាប្រជាជខ្មែរយើងត្រូវគេកាប់ហូរឈាមឥតការហើយអត់មានអង្គការណាមួយរកយុត្តិធម៌  វែកញែកទោសកំហុសអោយប្រជាជនខ្មែរ  អោយវាបានចូលជ្រាបអោយបានថាយល់ដឹងពីកំរិតទោសរបស់ប៉ុលពត ។

សុជាៈ   ពេលដែលតុលាការវែកមុខរកយុត្តិធម៌ជូនប្រជាជនហើយ     ដូចថាពូអីដែលជាជនរងគ្រោះដែលមានបងម្នាក់ឬក៏ពិបាកវេទនានៅក្នុងរបបនិងដែរ    ហើយបងម្នាក់ស្លាប់អញ្ចឹងពូអស់ចិត្តហើយនៅពេលដែលតុលាការស្វែងរកយុត្តិធម៌ជូនពូ?

ហឿនៈ   អស់ចិត្តហើយ ។

សុជាៈ   អញ្ចឹងរាល់ថ្ងៃនេះអត់ទាន់អស់ចិត្តទេ?

ហឿនៈ នៅតែដេររាល់តែថ្ងៃនិងឯង ចាំមើលអង្គការនិងស្វែងរកយុត្តិធម៌ជូនប្រជាជនហ្នឹង ចាំមើលថាកាត់ទោសៗតែវាមិនចេញនោះណា ចំណែកខ្លួនពូចាំមើលថាអ្នកដឹកនាំកំពូលៗដែលចេះដឹងជាងពូនិងថាតើវែកមុខវែកមាត់កាត់ទោសខ្មែរក្រហមកើតឬក៏មិនកើត ។

សុជាៈ អរគុណពូដែលបានផ្តល់បទសម្ភាសអោយពួកខ្ញុំសម្ភាស សូមអរគុណពូច្រើន ។

យោបល់អ្នកសម្ភាសៈបន្ទាប់ពីយើងបានសម្ភាសជាមួយម្ចាស់ប្រវត្តិម្នាក់រួចមក យើងបានជួបសមាសជាមួយនិងលោកពូម្នាក់ទៀតឈ្មោះ សន ហឿន សព្វថ្ងៃគាត់មានអាយុ៥២ឆ្នាំរស់នៅក្នុងភូមិអណ្តោត ឃុំបាក់ស្នាដែរនិងស្រុកបារាយណ៍ ខេត្តកំពង់ធំ ចំពោះការសម្ភាសនេះគាត់បានផ្តល់ពីជីវិតរបស់គាត់នៅក្នុងរឿងកាលពីសម័យខ្មែរក្រហមនិងពីរឿងការចាប់ខ្លួនរបស់យុទ្ធជនពីកម្មាភិបាលពីតំបន់ភូមិភាគបចិមនិងភូមិភាគកណ្តាល ពីខេត្តកំពង់ចាមពីខេត្តកពង់ធំនេះទៅហើយនិងការចាប់យុទ្ធជនកម្មាភិបាលនៅក្នុងកងពល៣១០ បន្ទាប់ពីការចាប់ខ្លួនរបស់អឿនដែលចោទថានិងបំរុងរៀបផែនការក្បត់ចង់វៃប៉ុលពតនោះ ចំនុចសំខាន់ពីដែលខ្ញុំសន្និដ្ឋានដែលមានលក្ខណៈពីអ្នកដទៃពិមុនមកនោះគឺទី១គាត់ចូលយុទ្ធជននៅឆ្នាំ១៩៧០ថ្ងៃ៨ខែ៨ នៅពេលដែលគាត់មានអាយុ១៨ឆ្នាំ ហើយពេលដែលគាត់ចូលទៅមុនដំបូងគាត់នៅទ័ពស្រុករហូតដល់ឆ្នាំ៧១បានគាត់ផ្លាស់ទៅធ្វើទ័ពនៅទ័ពមជ្ឈិម ហើយនៅឆ្នាំ៧២គាត់បានទៅវៃនៅសមរភូមិនៅខេត្តសៀមរាប ហើយទៅនៅខេត្តសៀមរាបនិងគាត់នៅបានជិត១ឆ្នាំ ហើយគាត់បានវៃនៅសមរភូមិអស់ជាច្រើននៅជិតប្រាសាទអង្គរវត្តនៅភ្នំបាក់ខែង ហើយវៃឡើងទៅជិតស្រុកបាត់ដំបងក្នុងស្រុកព្រះនេតព្រះ វៃទៅជិតឧត្តរមានជ័យ ហើយពត៏មាននេះគឺយើងមិនដែលលឺថាខាងខេត្តកំពង់ធំនេះទៅដល់ខាងខេត្តឧត្តមានជ័យដល់ខេត្តបាត់ដំបងទេគឺយើងគ្រាន់តែដឹងថា មួយចំនួនគាត់បានប្រាប់យើងថាបានទៅវៃនៅខេត្តសៀមរាបដែរ ហើយចំណែកពូគឺគាត់វៃមានរយះពេលវែងហើយទៅវៃច្រើនកន្លែងទៀតចំពោះពូផ្ទាល់គឺគាត់មាននាទីជាអនុប្រធានសេនាធំ តាមសំដីរបស់គាត់រឿងដែលសំខាន់មួយទៀតគឺការដែលគាត់ទៅប្រជុំជាមួយនិងអៀងសារី តាខៀវអ៊ីនិងអំពីការពង្រឹងនយោបាយរបស់ជនកម្មាភិបាលខ្មែរក្រហម នៅក្នុងពេលនិងអៀងសារី ខៀវសំផនហើយនិងតាខៀវបាននិយាយអំពីរឿងខ្សែរសេអ៊ីអានិងកាសេបេ ចំនុចនេះក៏យើងមានការចាបអារម្មណ៍ដែរហើយមួយទៀតគាត់ក៏បានឃើញគេធ្វើទារុណកម្មយុទ្ធជនកម្មាភិបាលពីភូមិភាគឧត្តរ ជាពិសេសគឺការចាប់ពូម្នាក់ឈ្មោះចនជាគណៈស្រុកបារាយណ៍គេយកទៅដាក់នៅគុកមួយជុំពេទ្យកាល់ម៉ែត្រ នេះហើយជាភស្តុតាង

មួយដែលមានការចាប់ខ្លួនមនុស្សនៅក្នុងរបបខ្មែរក្រហម ហើយអ៊ីត្រូវបានគេបញ្ជូនទៅធ្វើការនៅខេត្តកំពង់ឆ្នាំង តែគាត់ទៅវៃនៅវៀតណាមនោះគឺគាត់ទៅវៃបានតែ៣-៤ថ្ងៃទេ ហើយពួកវៀតណាមក៏បានចូលទីក្រុងភ្នំពេញ ហើយគាត់ក៏បានរត់ទៅកាន់ព្រំដែនថៃអស់មួយរយៈប្រហែលជាបានជិតមួយឆ្នាំបានគាត់វិលត្រឡប់មកស្រុកវិញ ហើយចំពោះការសន្និដ្ឋានរបស់យើងនៅក្នុងបទសម្ភាសនេះគឺយើងយល់ថាគាត់នៅមានរឿងជាច្រើនដែលគាត់និយាយមិនទាន់អស់ ហើយយើងគិតថានៅពេលក្រោយ យើងអាចទៅសម្ភាសគាត់បានមួយដងទៀត ដើម្បីសួរនាំពីចំនុចដែលយើងមានការសង្ស័យអំពីរឿងការចាប់ខ្លួន ពីព្រោះគាត់មានឋានៈធំដែររហូតដល់ប្រធានវរៈសេនាធំហើយគាត់អាចនៅទីក្រុងភ្នំពេញនិងបានទៅដល់ជិត៣ខែ ដោយមិនត្រូវគេបានចាប់ខ្លួនគាត់ចំពោះអ្នកដែលយើងសម្ភាសមុនៗគឺត្រឹមតែប្រធានកងហារអីហ្នឹង គឺត្រូវបានគេចាប់ខ្លួនហើយនៅពេលដែលគេចាប់កុយឃ្លួន ចាប់អឿននោះហើយ ។

**ចប**